





# ក្រមសីលធម៌នៃ អាកប្បកិរិយាសិស្ស ឆ្នាំ ២០១៧-២០១៨

**Code of Student Conduct**
**(Khmer)**





## ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

THE SCHOOL DISTRICT OF PHILADELPHIA


**គណៈកម្មាធិការកែទម្រង់សាលារៀន**

**ប្រធាន**

**Joyce S Wilkerson**

**សមាជិក**

**Feather Houston**
**Dr. Christopher McGinley**
**Farah Jimenez**
**Estelle B. Richman**

**អគ្គនាយកក្រសួងអប់រំ**

**Dr. William R. Hite, Jr.**

នាយិកា ផ្នែក គាំទ្រនៃការបម្រើសិស្សានុសិស្ស

**Karyn Lynch**


ក្រមសីលធម៌នៃអាកប្បកិរិយាសិស្សនឹងមាននៅក្នុងបែបផែនសម្រាប់រយៈពេលប្រាំឆ្នាំ ប៉ុន្តែ ***SRC*** អាចផ្លាស់ប្តូរបាន។


នាយិការង

ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស

**Rachel Holzman, Esq.**


ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស នឹងមានសុពលភាពរយៈពេលប្រាំឆ្នាំ ហើយអាចមានការផ្លាស់ប្តូរដោយគណកម្មាធិការកែទម្រង់សាលារៀន (SRC)។

## ការសច្ចាប្រណិធានរបស់សិស្ស

*ជាសិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ខ្ញុំសូមសច្ចាធ្វើតាម ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្ស* ***ដោយគោរពអ្នកដទៃ*** *និងខ្លួនខ្ញុំផ្ទាល់ ហើយប្រព្រឹត្តទៅលើអ្នកទាំងអស់ក្នុង សហគមន៍សាលារបស់ខ្ញុំតាម ភាពយុត្តិធម៌ និងចេះគិតដល់អ្នកដទៃ។*

*ខ្ញុំដឹង នឹងយល់ស្រប ថាសាលាត្រូវតែមានបរិយាកាសល្អ និងមានការសហការ ដើម្បីឲ្យយើងទាំងអស់គ្នាអាចសិក្សា។*

*ខ្ញុំដឹងថា ការមករៀនជារៀងរាល់ថ្ងៃ គឺជាគន្លឹះដ៏សំខាន់ដល់ជោគជ័យរបស់ខ្ញុំ។*

*ខ្ញុំដឹងថា អំពើហឹង្សា អាកប្បកិរិយាដែលធ្វើឲ្យរំខាន និងសំដីប្រមាថ គឺ***មិនអនុញ្ញាតឲ្យមាន*** *និងគ្មានការលើកលែងឲ្យបានទេ។*

*ដោយការចុះហត្ថលេខាលើពាក្យសច្ចានេះ ខ្ញុំយល់ និងទទួលខុសត្រូវតាម ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្សនេះ ដរាបណាខ្ញុំនៅតែជាសិស្ស នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។*

ហត្ថលេខារបស់សិស្ស៖ ____________________________________________

## ការសច្ចាប្រណិធានរបស់ មាតាបិតា/អាណាព្យាបាល/អ្នកមើលថែក្មេង

*ជាសមាជិកសហគមន៍សាលារបស់កូនខ្ញុំ ខ្ញុំបាន អាន និងយល់ពី ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្ស ហើយសុខចិត្តគាំទ្រគោលបំណងរបស់ក្រុមសីលធម៌នេះ ដរាបណាខ្ញុំនៅតែជាសមាជិកសហគមន៍សាលា។*

*ខ្ញុំដឹងថា ខ្ញុំមានតួនាទីដ៏សំខាន់ ក្នុងការរក្សាបរិយាកាស ដែលអបអរសាទរ ដល់ការសិក្សា។*

*ខ្ញុំនឹងយកចិត្តទុកដាក់ប្រាប់កូន អំពីសារៈសំខាន់នៃអាកប្បកិរិយាល្អ និងផលវិបាកផ្សេងៗដែលអាចកើតមាន បើសិនជាពួកគេប្រព្រឹត្តល្មើសនឹង ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្ស។*

*ខ្ញុំយល់ពីសារៈសំខាន់ និងបំណងចង់ឲ្យមានទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា នៅពេលណាមានការទាក់ទងនឹង អាកប្បកិរិយា និងការដាក់វិន័យ របស់កូនខ្ញុំ នៅសាលា។*

*ខ្ញុំសច្ចាថាផ្តល់នូវការគាំទ្រល្អៗ ដល់កូនរបស់ខ្ញុំ ដើម្បីជំរុញពួកគេឲ្យទៅរៀនជារៀងរាល់ថ្ងៃ និងដើម្បី ធ្វើឲ្យមានបរិយាកាសសិក្សាល្អ សម្រាប់សិស្សទាំងអស់។*

ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល/អ្នកមើលថែក្មេង៖________________________

## ការសច្ចាប្រណិធានរបស់ក្រសួងអប់រំ

*ជាសមាជិកនៃ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ខ្ញុំដឹងថា ខ្ញុំមានតួនាទីដ៏សំខាន់ក្នុងការផ្តល់បរិយាកាសល្អ និងមានសុវត្ថិភាព សម្រាប់សិស្សានុសិស្សទាំងអស់។ ខ្ញុំសូមសច្ចាដើម្បីធ្វើតាម ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្ស* ***ដោយគោរពអ្នកដទៃ*** *និងខ្លួនខ្ញុំផ្ទាល់ ហើយប្រព្រឹត្តទៅលើអ្នកទាំងអស់ក្នុងសហគមន៍សាលារបស់ខ្ញុំ តាមភាពយុត្តិធម៌ និងចេះគិតដល់អ្នកដទៃ។*

*ខ្ញុំសូមប្តេជ្ញា ដើម្បីអបអរសាទរដល់ការសិក្សា។*

*ខ្ញុំសូមប្តេជ្ញា ដើម្បីគាំទ្រដល់ ការបង្រៀន និងការសិក្សា ដោយបង្កើត និងរក្សានូវបរិយាកាសដែលមាន សុវត្ថិភាព សណ្តាប់ធ្នាប់ និងការចូលរួម។*

*ខ្ញុំសូមប្តេជ្ញា ដើម្បីធ្វើឲ្យមានទំនាក់ទំនងដែលមានការស្តាប់មតិគ្នាទៅវិញទៅមក ជាមួយសាលា និង សមាជិកសហគមន៍ ទាំងអស់។*

*ខ្ញុំសូមប្តេជ្ញាដើម្បីជំរុញការអនុវត្តន៍ ក្រុមសីលធម៌នៃអាកប្បកិរិយាសិស្ស តាមវិធីស្មើភាពគ្នា និងជាប់លាប់។*

ហត្ថលេខារបស់ បុគ្គលិករដ្ឋបាល៖______________________________

**សូមកត់សម្គាល់៖** ក្រមសីលធម៌នៃអាកប្បកិរិយាសិស្សទាំងអស់ មាននៅក្នុងវ៉ិបសៃរបស់ក្រសួង៖ http://www.philasd.org

លោកអ្នកអាចសុំក្រុមសីលធម៌មានជាសៀវភៅ ពីនាយកសាលារបស់លោកអ្នក ឬ ពីការិយាល័យទំនាក់ទំនងជាមួយក្រុមគ្រួសារ និង សហគមន៍ ដោយទូស័ព្ទទៅលេខ ២១៥-៤០០-៤១៨០ ឬ ចូលទៅវ៉ិបសៃ៖ http://webgui.phila.k12.pa.us/offices/p/publicengagement

បើចង់បានច្បាប់ចម្លងជាភាសាខ្មែរ សូមទាក់ទងទៅ មជ្ឈមណ្ឌលបកប្រែភាសា លេខ ២១៥-៤០០-៨៤៨៤ ឬ ចូលទៅវ៉ិបសៃ៖ https://webapps1.philasd.org/tdm/search/Khmer/yxzwCode#results

## គោលបំណងរបស់ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស

- ដើម្បីគាំទ្រដល់ការបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព សម្រាប់សមាជិកនៃសហគមន៍សាលាទាំងអស់។
- ដើម្បីបញ្ជាក់ឲ្យបានច្បាស់ និងជាក់លាក់ អំពីគោលបំណងដែលចង់បាន ចំពោះអាកប្បកិរិយានៃទំនាក់ទំនងនៅក្នុងសង្គម នៅគ្រប់មជ្ឈដ្ឋាននៃសាលាទាំងអស់។
- ផ្ដល់ឲ្យបុគ្គលិករដ្ឋបាលនូវការធ្វើអន្តរាគមន៍នៅសាលា ក្នុងការដោះ ស្រាយអាកប្បកិរិយាដែលនាំឲ្យរំខានរបស់សិស្ស។

## ច្បាប់របស់ក្រសួងអប់រំដែលទាក់ទងនឹងអាកប្បកិរិយា

**សុវត្ថិភាព និងសន្តិសុខ របស់សិស្សសាលាទាំងអស់ គឺជាកត្តាសំខាន់ បំផុតចំពោះយើង ហើយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ប្ដេជ្ញាផ្ដល់នូវមជ្ឈដ្ឋានសិក្សាដែលមានសុវត្ថិភាព។**

ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស បង្កើត ច្បាប់ វិន័យ និង បំណងប្រាថ្នាសម្រាប់សមាជិកនៃសហគមន៍សាលាទាំងអស់ ដើម្បី សិក្សា បង្រៀន និងរួមសហការ។

ការពិន័យ ចំពោះសិស្សដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពសាលា ឬរំខានដល់ការសិក្សារបស់សិស្សឯទៀត ក៏បានរៀបរាប់យ៉ាងលម្អិតដែរ។ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស អនុវត្តនៅម៉ោងរៀន និងពេលទៅ និងមកពីសាលា រួមទាំង តែគ្មានកំណត់ចំពោះ ការធ្វើដំណើរតាមយានជំនិះរបស់ក្រសួង និងប្រព័ន្ធយានជំនិះសាធារណៈ។

ក្រុមគ្រួសារ និងអាណាព្យាបាលសំខាន់ណាស់ចំពោះ សហគមន៍របស់យើង។ យើងខ្ញុំសំណូមពរសូមឲ្យគាត់អាន ហើយស្វែងយល់អំពី ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស និងកូនសៀវភៅណែនាំសិស្ស ហើយពិភាក្សាអ្វីៗទាំងនេះជាមួយកូន។ យើងខ្ញុំដឹងថា ក្រុមគ្រួសារ និងអាណាព្យាបាល ដឹងពីវិធីដ៏ល្អបំផុត ដើម្បីធ្វើយ៉ាងណាឲ្យកូនគាត់យល់ពីគោលបំណងដែលអាចធ្វើឲ្យ សហគមន៍មាន សុវត្ថិភាព និង របៀបរៀបរយ។

ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ផ្ដល់និយមន័យអំពីអាកប្បកិរិយាដែលល្មើស។ ទោះជានិយមន័យខ្លះមានរួមទាំងឧទាហរណ៍ អាកប្បកិរិយា រួមមាន តែគ្មានកំណត់ចំពោះ ឧទាហរណ៍ ដែលបានផ្ដល់ឲ្យ។

**មាតាបិតា អាណាព្យាបាល និង អ្នកមើលថែក្មេង ដែលមានសំណួរ ឬ ការបារម្ភអ្វី សូមទាក់ទងទៅ នាយកសាលា និង/ឬ ការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់សិស្ស លេខ ២១៥-៤០០-៨៤៨៤ ឬ វ៉ិបសៃ -**
http://webgui.phila.k12.pa.us/offices/s/student-rights-and-responsibilities

### ការទទួលខុសត្រូវ របស់គ្រូ

- គោរពសមាជិកនៃសហគមន៍សាលាទាំងអស់។
- ប្រើចំណេះដឹងក្នុងការដឹងនាំដែលបានរៀន ដើម្បីទប់ស្កាត់កុំឲ្យឧបត្តិហេតុតូចតាច ក្លាយទៅជាបញ្ហាធំ។

## អាកប្បកិរិយាដែលគេចង់បាន និងការទទួលខុសត្រូវផ្សេងៗ

### ការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប

- គោរពសមាជិកនៃសហគមន៍សាលាទាំងអស់។
- រក្សាបរិយាកាសល្អរបស់សាលាដោយមានការ ទទួលខុសត្រូវ ការគោរព និង ការសហការ។
- និយាយអំពីការដែលគេចង់បាននៅក្នុងក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស សម្រាប់ សិស្ស និង បុគ្គលិក។
- ជំរុញឲ្យសិស្សធ្វើឲ្យបានតាមការដែលលោសាចង់បាន តាមរយៈការលើកទឹកចិត្ត។
- ប្រើការថ្លឹងថ្លែងឲ្យបានល្អ ដើម្បីការពារឧប្បត្តិហេតុតូចតាច កុំឲ្យក្លាយទៅជាបញ្ហាធំ។

### ការទទួលខុសត្រូវរបស់រដ្ឋបាលសាលា

- គោរពសមាជិកនៃសហគមន៍សាលាទាំងអស់។
- អនុវត្ត ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស និងវិធីដាក់វិន័យ តាមវិធីស្មើភាពគ្នា និងជាក់លាក់។
- ផ្ដល់ឲ្យសិស្ស និងមាតាបិតា នូវ ច្បាប់នៃការដាក់វិន័យ ការជូនដំណឹង និង ឯកសារផ្សេងៗ ជាភាសាដែលពួកគាត់ត្រូវការ ដោយឥតគិតថ្លៃ។
- ជម្រាប បុគ្គលិកសាលា មាតាបិតា និងសិស្សានុសិស្សទាំងអស់ អំពីច្បាប់នៃការដាក់វិន័យ។
- ពិនិត្យ និងដោះស្រាយ ការចោទប្រកាន់ និងធ្វើតាមការស្នើសុំពីបុគ្គលិកសាលា ដែលទាក់ទងនឹងបទល្មើស។
- បង្រៀន និង រក្សា បរិយាកាសសិក្សា ដែលផ្ដល់ជោគជ័យក្នុងការសិស្សា។
- ឲ្យសិស្សទទួលខុសត្រូវចំពោះអំពើខុសឆ្គងដែលគេបានប្រព្រឹត្ត នៅក្នុងសាលា និង នៅក្នុងទីធ្លារបស់សាលា។
- លើកឡើងអំពីច្បាប់នៃការប្រព្រឹត្តបទល្មើស ជាមួយនឹងវិធីសាស្ត្រជាច្រើន ដើម្បីរក្សាសិស្សឲ្យមករៀន។
- ប្រើការថ្លឹងថ្លែងជាអ្នកជំនាញ ដើម្បីការពារឧប្បត្តិហេតុតូចតាច កុំឲ្យក្លាយទៅជាបញ្ហាធំ។
- ផ្ដល់ការហ្វឹកហ្វឺនដល់ គ្រូ និង បុគ្គលិក អំពី ការបង្កើត និង ការរក្សា ឲ្យបរិយាកាសរបស់សាលាមានការគោរពបញ្ហាវិន័យ ការបន្ធូបន្ថយបញ្ហា របួសផ្លូវចិត្តរបស់ក្មេង ការស្តារស្ថានភាពឡើងវិញ និងការហ្វឹកហ្វឺនដ៏ទៃទៀតដែលគ្រូនិងបុគ្គលិកបានស្នើសុំ ក្នុងគោលបំណងកែលម្អ បរិយាកាស និង សន្តិសុខ របស់សាលា និង/ឬ លទ្ធផលនៃការសិក្សារបស់សិស្ស។

### ការទទួលខុសត្រូវរបស់សិស្សានុសិស្ស

- គោរពសមាជិកនៃសហគមន៍សាលាទាំងអស់។
- យល់ដឹង និងគោរពតាម វិន័យ និងស្ថានភាពដែលគេចង់បាននៅសាលា រួមមាន ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស និងកូនសៀវភៅណែនាំសិស្ស។
- គោរពតាមច្បាប់ វត្តមានអវត្តមាន ការស្លៀកពាក់ យាយី និងច្បាប់នៃការសម្លុតធ្វើបាប។
- ធ្វើអាកប្បកិរិយាតាមលក្ខណៈដែលផ្ដោតទៅលើជោគជ័យនៃការសិក្សា។
- ចេះទទួលខុសត្រូវក្នុងការគោរពតាមវិន័យ។
- គោរព ប្រទេស និង ទង់ជាតិ របស់យើង (សិស្សអាចបដិសេធមិនសូត្រមបទគោរពទង់ជាតិ និងមិនគោរពទង់ជាតិដោយមូលហេតុ ជំនឿផ្ទាល់ខ្លួន ឬ ជំនឿសាសនា ក៏ប៉ុន្តែត្រូវតែគោរពដល់សិទ្ធិរបស់មិត្តរួមថ្នាក់ដ៏ទៃទៀតដែលចង់ចូលរួម)

### ការទទួលខុសត្រូវរបស់ មាតាបិតា/ អាណាព្យាបាល និង អ្នកគាំទ្រ

- គោរពសមាជិកនៃសហគមន៍សាលាទាំងអស់។
- គោរព យល់ និងគាំទ្រ វិន័យ និងច្បាប់របស់សាលា។
- គោរព យល់ និងគាំទ្រ ច្បាប់របស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។
- ទទួលស្គាល់ និងដឹងថា បុគ្គលិកសាលាត្រូវពង្រឹងវិន័យរបស់សាលា។
- បង្រៀនកូនឲ្យចេះគោរពសិទ្ធិរបស់អ្នកដ៏ទៃ និងធ្វើតាមវិន័យសាលា។
- បញ្ជាក់ពីសារៈសំខាន់នៃការត្រៀមខ្លួនជាមុន សម្រាប់ការសិក្សា និងធ្វើតាមវិន័យផ្សេងៗ របស់សាលា ដើម្បីជំរុញឲ្យមានជោគជ័យក្នុងការសិក្សា។

**បំណាងប្រាថ្នាចំពោះ ច្បាប់នៃការស្លៀកពាក់**

សិស្សទាំងអស់ត្រូវគោរពតាមច្បាប់នៃការស្លៀកពាក់របស់សាលា ដែលការស្លៀកពាក់មិនបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ សុខភាព ឬ សន្តិសុខ។ នាយកសាលាត្រូវធ្វើការសម្រេចចិត្ត និងប្រកាសការសម្រេចចិត្តចុងក្រោយបង្អស់ ថាតើសម្លៀកបំពាក់បែបណាដែលសមរម្យ ឬមិនសមរម្យ។ ដើម្បីជ្រាបព័ត៌មានអំពីច្បាប់នៃការស្លៀកពាក់របស់សាលា សូមអានកូនសៀវភៅណែនាំសិស្សរបស់សាលា។

ការបំពានលើច្បាប់នៃការស្លៀកពាក់មិនបណ្តាលឲ្យគេដកសិស្សចេញពីថ្នាក់រៀនទេ។ ការបំពានលើច្បាប់ឯកសណ្ឋានម្តងហើយម្តងទៀត អាចបណ្តាលឲ្យមានការឃាត់ខ្លួនទុកក្រៅម៉ោងបង្ហាត់បង្រៀន។

នាយកសាលាអាចប្រកាសថ្ងៃសម្រាប់ ជំរុញទឹកចិត្ត ឬក្លិប ហើយអនុញ្ញាតឲ្យសិស្សពាក់អាវដែលជួយជំរុញទឹកចិត្តរបស់សាលា ឬថ្ងៃស្លៀកពាក់ស្អាតបាត (ឧ. ពេលថតរូបនៅសាលា) ឬអនុញ្ញាតឲ្យសិស្សស្លៀកពាក់តាមរបៀបដែលសាលាតម្រូវ ដូចជា ឯកសណ្ឋាន ឬសម្លៀកបំពាក់ពិសេសសម្រាប់ ក្រុមយុវជន ក្រុមយុវតី (Boy Scouts, Girl Scouts) ក្រុមកីឡា ក្រុមអ្នករាំស្រែកលើកទឹកចិត្តក្រុមកីឡា ក្រុមភ្លេង ឬចម្រៀងជាពួក។ នៅក្នុងក្រមសីលធម៌នៃអាកប្បកិរិយាសិស្សនេះ គ្មានការដាក់កំណត់ ឬហាមមិនឲ្យសិស្ស ស្លៀកពាក់សម្លៀកបំពាក់សាសនាទេ។ មាតាបិតាដែលមានការបារម្ភអំពីសម្លៀកបំពាក់សាសនា ត្រូវបានគេជំរុញឲ្យពិភាក្សាពីការបារម្ភទាំងនេះ ជាមួយនាយកសាលា។

សិស្សមានសិទ្ធិស្លៀកពាក់ស្របទៅតាមភេទរបស់ពួកគេ និង/ឬ ទៅតាមច្បាប់នៃការស្លៀកពាក់របស់សាលា។

**បើមានសំណួរបន្ថែមទៀតដែលទាក់ទងនឹងច្បាប់នៃការស្លៀកពាក់ អាចសួរទៅនាយក ឬ អ្នកតំណាងរបស់ គាត់។**

### ការតម្រូវចំពោះ វត្តមានអវត្តមាន

**បំណាងប្រាថ្នាចំពោះ វត្តមានអវត្តមាន**

ក្នុងតំបន់ហ្វីឡាដែលហ្វ្យា ក្មេងទាំងអស់ដែលមានអាយុ ពី៦ ដល់១៧ ឆ្នាំ ត្រូវ គេតម្រូវឲ្យចូលរៀន។ «ចូលរៀន» មានន័យថា ក្មេងត្រូវតែចុះឈ្មោះ ហើយទៅរៀននៅ សាលារដ្ឋ សាលាឆាទ័រ សាលាឆាទ័រដែលរៀនតាមអ៊ិនធ័រណិត សាលាឯកជន ឬសាលាសាសនា ឬចូលរួមក្នុងកម្មវិធីរៀននៅផ្ទះដែលគេបានទទួលស្គាល់។ នៅពេលដែលសិស្សមានអាយុ ៥ ឆ្នាំ ឬច្រើនជាងនេះមកចុះឈ្មោះចូលរៀន សិស្សនោះត្រូវគេចាត់ទុកថាជាក្មេងដែលមានអាយុត្រូវទៅសាលា ហើយគេតម្រូវឲ្យសិស្សនោះមករៀនជារៀងរាល់ថ្ងៃ។ បើសិនជា សិស្ស/ក្រុមគ្រួសារ មិនបានធ្វើតាមនេះទេ គេអាចបញ្ជូនទៅ DHS ដើម្បីទទួលការបម្រើផ្នែកបញ្ហានៃការគេចសាលា។

បទបញ្ជារបស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា បានចែងថា ក្មេងត្រូវបានគេគិតថាមានអាយុចូលរៀន ចាប់ពីពេលដែលពួកគេបានទទួលឲ្យចូលរៀននៅកម្មវិធីសិក្សាសាលារដ្ឋ រហូតដល់រៀនចប់ពី វិទ្យាល័យ ឬពេលមានអាយុ២១ឆ្នាំ។ ហេតុដូច្នេះ ក្នុងកំឡុងពេលដែលក្មេងគ្រប់អាយុចូលរៀន ក្មេងមានសិទ្ធិទៅរៀននៅសាលារដ្ឋ ដែលជាក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ឬក៏សាលាឆាទ័រ។ សិស្សដែលមានអាយុ២១ឆ្នាំ ក្នុងកំឡុងឆ្នាំសិក្សា មានសិទ្ធិបញ្ចប់ការសិក្សានៅក្នុងឆ្នាំសិក្សានោះបាន។

មាតាបិតា/អាណាព្យាបាល ទាំងអស់ត្រូវគេកំណត់ឲ្យ៖

- ធ្វើយ៉ាងណាឲ្យកូនដែលមានអាយុពី៦ដល់១៧ឆ្នាំ ចុះឈ្មោះរៀន ហើយទៅរៀនឲ្យបានទៀងទាត់ ទាន់ពេលវេលា និងពេញមួយថ្ងៃសិក្សា។
- បញ្ជាក់ពីសារៈសំខាន់នៃការទៅឲ្យបានទាន់ពេលវេលា ពេលទៅ សាលា ថ្នាក់រៀន និងសកម្មភាពដែលមានអ្នកមើលខុសត្រូវ—ហើយអបអរសាទរដល់ ការមករៀនទៀងទាត់ និងជោគជ័យ របស់សិស្ស។
- បញ្ជូនកូនទៅរៀនរាល់ថ្ងៃ ដោយបានត្រៀមខ្លួនជាស្រេចដើម្បី ចូលរួម និងរៀនសូត្រ ដោយឲ្យកូនគេងឲ្យបានគ្រប់គ្រាន់ និង ផ្តល់អាហារពេលព្រឹក។
- ដាក់បម្រាមគោចរ/កំណត់ពេលចូលគេង ដែលសមរម្យតាមអាយុ។
- ធ្វើការណាត់ជួបឲ្យកូន ក្រៅពីថ្ងៃរៀន ឬនៅពេលសាលាឈប់សម្រាក តាមការដែលអាចធ្វើទៅបាន។
- ធ្វើយ៉ាងណាឲ្យកូនទទួលការពិនិត្យសុខភាព ឲ្យបានទៀងទាត់ តាមការតម្រូវរបស់ច្បាប់។
- យកពេលដើរកំសាន្តជុំគ្រួសារ នៅពេលសាលាមានវិស្សមកាល។
- ទូរស័ព្ទទៅសាលា ពេលណាកូនអវត្តមាន។
- ផ្តល់លិខិតជម្រាបពីមូលហេតុ រាល់អវត្តមាន នៅពេលសិស្សត្រឡប់មករៀនវិញ។
- ផ្តល់លិខិតជម្រាបពីមូលហេតុ រាល់ពេលសិស្ស មករៀនយឺតពេល និងចេញទៅផ្ទះមុនម៉ោង។
- ផ្តល់អាស័យដ្ឋានដែលរស់នៅសព្វថ្ងៃ ព័ត៌មានសម្រាប់ទាក់ទងពេលមានអាសន្ន លេខទូរស័ព្ទផ្ទះ និងកន្លែងធ្វើការ អ៊ីមែល ឲ្យបានត្រឹមត្រូវទៅឲ្យសាលា នៅពេលចាប់ផ្តើមឆ្នាំសិក្សាម្តងៗហើយផ្តល់ព័ត៌មានថ្មីៗ នៅពេលណាមានការផ្លាស់ប្តូរ។
- ជួយរៀបចំ និងអនុវត្ត គម្រោងការសម្រាប់សិស្សម្នាក់ៗ សម្រាប់កែលម្អអវត្តមានរបស់កូនលោកអ្នក នៅពេលណាចាំបាច់។

### តើក្មេងអាចអវត្តមាននៅពេលណា?

ពេលខ្លះសិស្សមិនអាចទៅរៀនបាន។ ពេលទាំងនេះហៅថា "អវត្តមានដោយមានមូលហេតុ" ជាអវត្តមានក្នុងកាលៈទេសៈដូចជា មានជម្ងឺ ឬមានរបួស យុវវ័យដែលជាមាតាឈប់សម្រាក (ប្រាំមួយសប្តាហ៍ ឬ៣០ថ្ងៃ នៃថ្ងៃសិក្សា) ក្រោយពេលឆ្លងទន្លេរួច) អវត្តមានដែលទាក់ទងនឹង មរណភាព/បុណ្យសព ដំណើរកំសាន្ត ឬសកម្មភាព ដែលទាក់ទងនឹងការសិក្សា ការពិន័យមិនឲ្យមករៀនបណ្តោះអាសន្ន និងថ្ងៃសម្រាកពេលមានបុណ្យសាសនា។ ត្រូវប្រគល់លិខិតពីមាតាបិតា ឬអាណាព្យាបាល ឲ្យទៅសាលាជាបន្ទាន់ នៅពេលសិស្សត្រឡប់មករៀនវិញ។ លិខិតនេះត្រូវមានលេខទូរស័ព្ទ ឬអ្វីផ្សេងទៀតដែលអាចទាក់ទងបាន សម្រាប់ការសួរបញ្ជាក់។ បើអវត្តមាន មានចំនួនពី៣ថ្ងៃ ផ្ទួនៗគ្នាឡើងទៅ គេតម្រូវឲ្យមានលិខិតបញ្ជាក់ពី ជម្ងឺ/របួស/ឆ្លងទន្លេ។ សិស្ស/ក្រុមគ្រួសារ មានពេលបីថ្ងៃ ចាប់ពីថ្ងៃអវត្តមាន ដើម្បីផ្តល់ឯកសារទៅឲ្យសាលាសម្រាប់អវត្តមានដែលមានមូលហេតុ។ ក្រោយពីបីថ្ងៃ នាយកសាលា ឬអ្នកតំណាងរបស់គាត់ អាចយល់ព្រម ឬបដិសេធ លិខិតនោះ។

«អវត្តមានដែលគ្មានមូលហេតុ» ឬ «អវត្តមានខុសច្បាប់» គឺនៅពេលដែលសិស្សអវត្តមានដោយគ្មានមូលហេតុ ត្រឹមត្រូវតាមការសរសេរ។ នោះមានន័យថា គ្មានលិខិតប្រគល់ឲ្យទៅសាលានៅពេលសិស្សត្រឡប់មករៀនវិញ ឬមូលហេតុនៅក្នុងលិខិតនោះ មិនមែនជាមូលហេតុត្រឹមត្រូវ។ ឧទាហរណ៍នៃមូលហេតុដែលមិនត្រឹមត្រូវមាន (ប៉ុន្តែគ្មានកំណត់) មើលថៃក្មេង ងើបពីគេងមិនទាន់ពេល ឬ ទៅដើរលេងជាមួយក្រុមគ្រួសារ។

ព័ត៌មានបន្ថែមអំពី វត្តមានអវត្តមាន និង ការគេចសាលា មាននៅក្នុងវ៉ិបសៃ វត្តមានអវត្តមាន និង ការគេចសាលា របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា-http://webgui.phila.k12.pa.us/offices/a/attendance--truancy

## ការឆ្លើយតបទៅនឹង ការមិនមករៀន (ការគេចសាលា)

សិស្សដែលអវត្តមានដោយគ្មានមូលហេតុ បី (៣) ដង ឬច្រើនជាំងនេះ រាប់ថាជាការ "គេចសាលា"។ នៅពេលណាសិស្សគេចសាលា សាលាត្រូវតែផ្តល់ដំណឹងដល់ មាតាបិតា/អាណាព្យាបាល ជាលាយលក្ខណ៍អក្សរ តាមរយៈលិខិត Three Day Legal Notice។ លិខិតនេះត្រូវសរសេរជាភាសាដែល មាតាបិតា/អាណាព្យាបាល ចង់បាន។ នៅក្នុងលិខិតនោះអាចមានសំណូមពរសូមឲ្យមានការជួបប្រជុំដើម្បីកែលម្អវត្តមានអវត្តមានរបស់សិស្ស។ កម្រិតរបស់សាលា ការគេចសាលាអាចនាំមកនូវការធ្វើអន្តរាគមន៍ផ្សេងៗពីសាលា (ទៅជួបនៅផ្ទះ ផែនការកែលម្អវត្តមានអវត្តមាន (MTSS) ការបញ្ជូនឲ្យទៅខាងការបម្រើផ្នែក ជំនួយក្នុងការសិក្សា និង សង្គម)។ បើសិនជាក្មេងដែលគេចសាលានោះ នៅតែបន្តអវត្តមានដោយគ្មានមូលហេតុ គេតម្រូវឲ្យសាលាអញ្ជើញក្រុមគ្រួសារឲ្យមកសាលា ដើម្បីជួបប្រជុំអំពីការកែលម្អវត្តមានអវត្តមាន។ គេត្រូវតែហៅ មាតាបិតា និង កូន ឲ្យមកចូលរួមអង្គប្រជុំនេះ ក៏ប៉ុន្តែគេមិនតម្រូវឲ្យពួកគេត្រូវតែមកចូលរួមនោះទេ។ នៅក្នុងអង្គប្រជុំ គេត្រូវតែជជែកពីមូលហេតុដែលសិស្សអវត្តមាន ហើយសាលាត្រូវតែបង្កើតផែនការដើម្បីជួយដោះស្រាយបញ្ហាដែលសិស្សកំពុងតែប្រឈម ដែលរារាំងមិនអាចឲ្យសិស្សមករៀនបាន។

សិស្សដែលអវត្តមាន ប្រាំមួយ (៦) ដង ឬច្រើនជាងនេះ ក្នុងឆ្នាំសិក្សា គេចាត់ទុកថាជា «ទម្លាប់គេចសាលា»។ នៅពេលណាក្មេងមានទម្លាប់គេចសាលា គេអាចបញ្ជូន ក្មេងនោះ និង ក្រុមគ្រួសារ ទៅតុលាការផ្នែកក្មេងគេចសាលាក្នុងតំបន់ ឬទៅ DHS គឺអាស្រ័យទៅលើអាយុរបស់ក្មេង។ មុននឹងការបញ្ជូនទៅ តុលាការផ្នែកក្មេងគេចសាលា ឬទៅ DHS គេតម្រូវឲ្យសាលាអញ្ជើញក្រុមគ្រួសារមកសាលាដើម្បីប្រជុំអំពីការកែលម្អវត្តមានអវត្តមាន និង បង្កើតផែនការដើម្បីជួយដល់ការកែលម្អវត្តមានអវត្តមាន (MTSS)។ សាលាត្រូវតែបញ្ជាក់អំពីផែនការនេះ ទៅជាមួយការបញ្ជូនណាមួយ។

នៅពេលដែលគេបញ្ជូនក្មេងទៅតុលាការផ្នែកក្មេងគេចសាលា គេនឹងចាត់តាំងអ្នកចាត់ការផ្នែកក្មេងគេចសាលាទៅធ្វើការជាមួយក្រុមគ្រួសារ ដើម្បីដោះស្រាយបញ្ហាដែលសិស្សកំពុងតែប្រឈម អំពីការគេចសាលា។

គេតម្រូវឲ្យ សិស្ស និង មាតាបិតា/អាណាព្យាបាល ទៅតុលាការផ្នែកក្មេងគេចសាលា ដើម្បីពិភាក្សាអំពីវត្តមានអវត្តមានរបស់ក្មេង។ មាតាបិតា/អាណាព្យាបាល ត្រូវតែគោរពតាមបញ្ជារបស់តុលាការផ្នែកក្មេងគេចសាលា។ បទបញ្ជារបស់តុលាការអាចរួមបញ្ចូល ការបញ្ជូនទៅដើម្បីទទួលជំនួយ។ បើសិនជាវត្តមានរបស់សិស្សគ្មានលក្ខណៈល្អប្រសើរ តុលាការផ្នែកក្មេងគេចសាលាអាចបញ្ជូនសំណុំរឿងនេះទៅ តុលាការសម្រាប់ក្រុមគ្រួសារ។ នៅក្នុងតុលាការសម្រាប់ក្រុមគ្រួសារ ចៅក្រមអាចវិនិច្ឆ័យទៅលើភាពឯករាជ្យរបស់ក្មេង ហើយអាចបញ្ជាឲ្យដកក្មេងចេញពីផ្ទះរបស់ខ្លួន ទៅដាក់នៅកន្លែងឲ្យគេជួយចិញ្ចឹម ឬនៅកន្លែងដែលរស់នៅជាក្រុម ណាមួយ។

**ការបញ្ឈប់មិនឲ្យសិស្សមករៀនបណ្តោះអាសន្ន ឬ ការប្តូរទៅមជ្ឈដ្ឋានអប់រំតាមទម្រង់ផ្សេងទៀត គឺមិនមែនជាការឆ្លើយតបដែលគេអនុញ្ញាតឲ្យធ្វើចំពោះការគេចសាលានោះទេ។**

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី វត្តមានអវត្តមាន និង ការគេចសាលា សូមមើលវ៉ិបសៃរបស់ក្រសួងអប់រំ - http://webgui.phila.k12.pa.us/offices/a/attendance--truancy

### អ្នកដែលមកកាន់បរិវេណសាលា

គេជំរុញឲ្យ មាតាបិតា និងអាណាព្យាបាល មកកាន់សាលា ហើយជួបជាមួយ គ្រូ និងរដ្ឋបាល អំពីការរីកចម្រើនរបស់កូនគាត់។ អ្នកមកកាន់បរិវេណសាលា ត្រូវតែបង្ហាញខ្លួននៅការិយាល័យរបស់សាលា ជាមួយអត្តសញ្ញាណប័ណ្ណដែលមានរូបថត។ ដើម្បីផ្តល់បរិយាកាសសិក្សាដែលមានសន្តិសុខ និងមានសណ្តាប់ធ្នាប់ ភ្ញៀវដែលមកកាន់ទីធ្លាសាលារដ្ឋ ឬអាគារសាលារដ្ឋ ត្រូវមានការអនុញ្ញាតពីនាយកសាលា ឬពីអ្នកតំណាងរបស់គាត់។

### តើនៅពេលណាដែលគេអនុវត្តច្បាប់នេះ?

ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស គឺសម្រាប់ឲ្យសិស្សទាំងអស់គោរពតាម នៅពេលធ្វើដំណើរ ទៅ ឬ មកពីសាលា ការដឹកជញ្ជូនគ្រប់រូបភាព ព្រមទាំងនៅពេលមានកម្មវិធីដែលទាក់ទងនឹងសាលា។ ជាបន្ថែមទៀត ច្បាប់នេះគឺសម្រាប់អនុវត្តចំពោះអាកប្បកិរិយាដែលរំខាន នៅក្រៅទីធ្លាសាលា និង ក្រោយម៉ោងសិក្សា ផងដែរ បើសិនជាជាប់ទាក់ទងជាមួយសាលា និង បរិស្ថានសិក្សា ដែលសាលាផ្តល់ឲ្យ។

### ការបញ្ជូនទៅឲ្យភ្នាក់ងារប៉ូលីសប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា

បទល្មើសនឹង ក្រមសីលធម៌នៃអាកប្បកិរិយាសិស្សខ្លះ ក៏អាចជាបទព្រហ្មទណ្ឌដែរ។ កំណត់ហេតុនៃការយល់ដឹង (MOU) បានចុះអំពីបទព្រហ្មទណ្ឌដែល*ត្រូវ*រាយការណ៍ទៅស្នងការប៉ូលីសប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ជាបន្ថែមទៀត ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានកំណត់ហេតុនៃការយល់ដឹង ជាមួយស្នងការប៉ូលីសប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា បញ្ជាក់ពីកម្មវិធីចម្រុះ ដែលជំនួសឲ្យ ការចាប់ខ្លួន និងការដាក់ទោសព្រហ្មទណ្ឌ។

កំណត់ហេតុនៃការយល់ដឹងទាំងអស់ មាននៅក្នុងវ៉ិបសៃរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា - http://philasd.org/announcements/MOU-Between-PPD-and-SDP-2014.pdf

### កម្មវិធីជួយសម្រួលផ្សេងទៀត

ស្នងការប៉ូលីសនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា នឹងមិនចាប់សិស្សទេ បើសិនជាសិស្សនោះបានប្រព្រឹត្តិបទល្មើសដែលមិនមែនជាអំពើហឹង្សានៅសាលា ហើយមិនធ្លាប់មានការចាប់ខ្លួនពីមុន។ ក្នុងករណីទាំងនេះ សិស្សនឹងទទួលការបម្រើពីក្រសួងមនុស្សធម៌។

នាយកសាលា គ្រូបង្រៀន និងបុគ្គលិកសាលាផ្សេងទៀត មានបំណងចង់ឲ្យសិស្សមាន ការសិក្សា និងអាកប្បកិរិយាល្អ។ មនុស្សពេញវ័យនៅសាលាជួយសិស្សឲ្យមានជោគជ័យ ផ្ទាល់ខ្លួន និងក្នុងការសិក្សា តាមការប្រើនូវវិធីឆ្លើយតបជាច្រើនបែប។

វិធីរៀបចំថ្នាក់រៀនទាំងនោះរួមមាន៖

- ធ្វើឲ្យសិស្សចាប់អារម្មណ៍ ដោយហៅឈ្មោះរបស់ពួកគេដោយសម្លេងទន់ភ្លន់។
- ដោះស្រាយបញ្ហាជាមួយសិស្សនៅកន្លែងដែលគ្មានសិស្សឯទៀត
- និយាយពីបញ្ហានៃអាកប្បកិរិយានោះ

- ប្រាប់ពីអកប្បកិរិយាដែលសាលាចង់បាន និងមូលហេតុដែលសិស្សត្រូវធ្វើតាមអាកប្បកិរិយានោះ
- ស្តាប់ការឆ្លើយតបរបស់សិស្ស ហើយជួយសិស្សឲ្យដឹងអាកប្បកិរិយាដែលសមរម្យរបស់គេ។
- បញ្ជាក់ចំៗនូវផលវិបាក ចំពោះការបន្តធ្វើអាកប្បកិរិយាមិនល្អ—និងផលវិជ្ជមាននៃអាកប្បកិរិយាល្អ។
- សុំឲ្យសិស្សបង្ហាញពីអាកប្បកិរិយាដែលគេចង់បាន។
- ទទួលស្គាល់សិស្សណាដែលចេះស្តាប់អ្នក និង/ឬ មានអាកប្បកិរិយាសមរម្យ (ឧ. អរគុណ សរសើរ ឲ្យរង្វាន់ ។ល។)
- កត់ទុកនូវបទល្មើសលើរបាយការណ៍បញ្ជូនសិស្សសម្រាប់ការដាក់វិន័យ (EH20-លិខិតពណ៌ផ្កាឈូក)
- ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីវិធីសាស្ត្រនៃការគ្រប់គ្រងថ្នាក់រៀន សូមទូរស័ព្ទទៅ ការិយាល័យផ្នែក បរិយាកាស និង សន្តិសុខ របស់សាលា។

ការធ្វើអន្តរាគមន៍របស់សាលា អាចមានអ្វីៗទាំងអស់ដូចតទៅនេះ៖

- សរសេរកិច្ចសន្យានៃអាកប្បកិរិយា
- ការឃាត់ខ្លួនទុក មុន និង ក្រោយ ម៉ោងរៀន
- ការស្ម័គ្រចិត្តជួយធ្វើការផ្សេងៗ (ឧ. នៅផ្ទះបាយ ជម្រកបណ្តោះអាសន្ន)
- ជួយធ្វើការនៅសាលញ៉ាំបាយ
- ការប្រជុំនៅក្នុងសហគមន៍/ការស្តារយុត្តិធម៌ឡើងវិញ
- ការបញ្ជូនរបស់អ្នកផ្តល់ឱវាទរបស់សាលា សម្រាប់ការឲ្យយោបល់ដល់សិស្សម្នាក់ៗ និង/ឬ ជាក្រុម និង ការវាយតម្លៃផ្លូវចិត្តរបស់សិស្សម្នាក់ៗ និង ជំនួយដែលពាក់ព័ន្ធ
- ធ្វើកិច្ចការនៅសាលាដោយលម្អិត
- ការឃាត់ខ្លួនទុកនៅពេលញ៉ាំអាហារថ្ងៃត្រង់
- មាតាបិតាមកឃ្លាំមើលកូននៅសាលា
- ការដោះស្រាយទំនាស់រវាងមិត្តភ័ក្តិ
- សរសេរឆ្លុះបញ្ចាំងអំពីអ្វីដែលបានធ្វើ
- សិក្សាដោយខ្លួនឯង
- ការប្រជុំរវាង សិស្ស/គ្រូ/មាតាបិតា
- របាយការណ៍ប្រចាំថ្ងៃ/តារាងកាលវិភាគផ្ទាល់ខ្លួន
- ការស្តារឡើងវិញ
- កម្មវិធីតាមឃ្លាំមើល
- កំណត់ហេតុនៅពេល ចេញ/ចូល
- កម្មវិធីផ្នែកលើកស្ទួយតាងនៃដំណាក់កាលទី II (Tier II)
- ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ការធ្វើអន្តរាគមន៍ទូទាំងសាលា សូមទូរស័ព្ទទៅ ការិយាល័យផ្នែក បរិយាកាស និង សន្តិសុខ របស់សាលា។
- ការវាយតម្លៃអាកប្បកិរិយាសម្រាប់គម្រោងការនៃអាកប្បកិរិយារបស់សិស្សម្នាក់ៗ ការអនុវត្តន៍ និង ការតាមដានការរីកចម្រើន
- បញ្ជូនទៅ SAP (កម្មវិធីផ្តល់ជំនួយដល់សិស្ស) សម្រាប់ការវាយតម្លៃផ្លូវចិត្ត និង ការបញ្ជូមដែលសមរម្យ។
- បញ្ជូនទៅកម្មវិធីព្យាបាលនៅតាមសាលា (STS, CASST)
- ប្រជុំរវាងអង្គការផ្សេងៗ ជាមួយសាលា មាតាបិតា អង្គការផ្នែកសុខភាពផ្លូវចិត្ត
- ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ការធ្វើអន្តរាគមន៍ផ្នែកផ្លូវចិត្តរបស់សិស្សម្នាក់ៗ និង កម្មវិធីព្យាបាលនៅតាមសាលា សូមទូរស័ព្ទទៅ ការិយាល័យផ្នែក ការពារ និង ធ្វើអន្តរាគមន៍
- សម្រាប់ភាពអាសន្នផ្នែក បញ្ហា ខួរក្បាល/ផ្លូវចិត្ត សូមទូរស័ព្ទទៅលេខសម្រាប់ស្ថានភាពអាសន្ន ២៦៧-៧៨៤-៧៨៩៥
- ចំពោះការចោទប្រកាន់នៃ ការធ្វើបាប/មិនយកចិត្តទុកដាក់ សូមទូរស័ព្ទទៅលេខសម្រាប់ជួយកុមារ ៨០០-៩៣២-០៣១៣

**ការបញ្ឈប់បណ្តោះអាសន្ននៅក្រៅសាលាជាមធ្យោបាយចុងក្រោយបង្អស់ និងនៅពេលណាមាន អន្តរាគមន៍ និងការដាក់វិន័យ នៅក្នុងសាលា មិនគ្រប់គ្រាន់ដើម្បីដោះស្រាយអាកប្បកិរិយាដែលមិនសមរម្យរបស់សិស្ស។**

| អាកប្បកិរិយាដែលធ្វើឲ្យរំខាន | វិន័យ | កម្រិតនៃការដាក់ទណ្ឌកម្ម | | | | |
|---|---|---|---|---|---|---|
| | | កម្រិតទី ១៖ ការធ្វើអន្តរាគមន៍នៅក្នុងសាលា (រួមទាំងការដាក់ទណ្ឌកម្មនៅក្នុងសាលា) | កម្រិតទី ២៖ ការបញ្ឈប់បណ្ដោះអាសន្ននៅក្រៅសាលា | កម្រិតទី ៣៖ កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬប្ដូរទៅកន្លែងផ្សេង | កម្រិតទី ៤៖ បញ្ជូនទៅសាលាដែលមានវិន័យ តឹងតែង | កម្រិតទី ៥៖ បញ្ជូនទៅសាលាដែលមានវិន័យតឹងតែង ជាមួយនឹងការបញ្ជូនដើម្បីបណ្ដេញចេញ |
| | | | | ការដាក់ទណ្ឌកម្ម កម្រិតទី ៣ ៤ ឬ ៥ តម្រូវឲ្យមានការបញ្ជូនទៅ ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវរបស់សិស្ស។ | | |
| មិនគោរពធ្វើតាមវិន័យរបស់ថ្នាក់រៀន/ធ្វើឲ្យមានការរំខាន | ១ក | ✓ | | | | |
| មិនកាន់ស្លាកដើរក្នុងអាគារ ឬគ្មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ | ១គ | ✓ | | | | |
| គេចមិនមករៀន/មករៀនយឺតពេលច្រើនដង/គេចមិនចូលថ្នាក់រៀន | ២ | ✓ | | | | |
| មានរបស់ផ្ទាល់ខ្លួនដែលមិនសមរម្យ | ៣ខ | ✓ | | | | |
| ប្រើពាក្យ ឬកាយវិការ ដែលប្រមាថមើលងាយ | ៤ | ✓ | | | | |
| ប្រើគ្រឿងអេឡិចត្រូនិច មិនសមរម្យ | ៥ខ | ✓ | ✓ | ✓ | ✓ | ✓ |
| ការវាយតប់គ្នាទៅវិញទៅមក (ដោយគ្មានរបួសធ្ងន់ធ្ងរ) | ៦ | ✓ | ✓ | | | |
| ការក្លែងបន្លំហត្ថលេខា របស់ រដ្ឋបាល គ្រូបង្រៀន ឬមាតាបិតា/អាណាព្យាបាល | ៧ | ✓ | ✓ | | | |
| បំផ្លែង របាយការណ៍ពិន្ទុ មូលហេតុពីការឈឺស្កាត់ និង/ឬ ឯកសារសាលាផ្សេងៗទៀត | ៨ | ✓ | ✓ | ✓ | ✓ | |
| បំផ្លាញ និង/ឬ លួចរបស់ទ្រព្យ (តិចជាង ៥០០$) | ៩ | ✓ | ✓ | ✓ | | |
| ការយាយី (រួមទាំងការយាយីផ្លូវភេទ) | ១០ក | ✓ | ✓ | ✓ | ✓ | ✓ |
| ការសម្លុតធ្វើបាប/ការសម្លុតធ្វើបាបតាមគ្រឿងអេឡិចត្រូនិច | ១០ខ | ✓ | ✓ | ✓ | ✓ | ✓ |
| ការគម្រាមកំហែង | ១០គ | ✓ | ✓ | ✓ | ✓ | ✓ |
| ការសេពមេថុន (ដោយការយល់ព្រម) | ១១ | ✓ | ✓ | ✓ | | |
| ការគម្រាមកំហែងដល់ សិស្ស/បុគ្គលិក ថានឹងវាយតប់គេយ៉ាងធ្ងន់ធ្ងរ | ១២ | | ✓ | ✓ | ✓ | ✓ |
| បំផ្លាញ និង/ឬ លួចរបស់ទ្រព្យ (ចំនួន ៥០០$ ឬច្រើនជាងនេះ) | ១៣ | | ✓ | ✓ | ✓ | |
| វាយបំបាក់ ហើយចូលក្នុងអាគារសាលា | ១៤ | | ✓ | ✓ | ✓ | |
| ចោរកម្ម | ១៥ក | | ✓ | ✓ | ✓ | ✓ |
| ការជំរិតយកប្រាក់ | ១៥ខ | | ✓ | ✓ | ✓ | ✓ |
| ការវាយតប់គ្នាទៅវិញទៅមក (មានឯកសារបញ្ជាក់ថាមានរបួសធ្ងន់ធ្ងរ) | ១៦ | | ✓ | ✓ | ✓ | |
| ការវាយតប់សមាជិករបស់សហគមន៍សាលា | ១៧ | | ✓ | ✓ | ✓ | |
| មានគ្រឿងស្រវឹង និង/ឬ គ្រឿងញៀន | ១៨ | | ✓ | ✓ | ✓ | ✓ |
| មាន ឬប្រើ កាំជ្រួច/គ្រឿងផ្ទុះផ្សេងៗ/គ្រឿងឆេះ | ១៩ | | ✓ | ✓ | ✓ | ✓ |
| នាំរឿង ឬចូលរួមក្នុងក្រុមវាយតប់គេ | ២១ | | ✓ | ✓ | ✓ | ✓ |
| ការវាយតប់គេ | ២២ | | | ✓ | ✓ | ✓ |
| ការសេពមេថុន (គ្មានការយល់ព្រម) | ២៣ | | ✓ | ✓ | ✓ | ✓ |
| មានគ្រឿងអាវុធ | ២៤ | | | | ✓ | ✓ |
| មិនប្រយ័ត្ន ធ្វើឲ្យអ្នកណាម្នាក់ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ | ២៥ | | ✓ | ✓ | ✓ | ✓ |

**'កម្រិតនៃការដាក់ទណ្ឌកម្ម មិនរាប់បញ្ចូលទាំងស្រុងទេ។ បើសិនជាសិស្សត្រូវគេបញ្ជូនទៅ ការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់សិស្ស សិស្សនោះក៏ត្រូវគេបញ្ឈប់មិនឲ្យមកសាលាបណ្ដោះអាសន្ន រយៈពេលពី ១ – ១០ ថ្ងៃ។** សូមកត់សម្គាល់ថា សវនាការដាក់ទណ្ឌកម្ម សម្រាប់**តែ** សិស្សថ្នាក់ទី៦ ដល់ថ្នាក់ទី១២។ **គ្មាន**ការ បញ្ឈប់មិនឲ្យមកសាលាបណ្ដោះអាសន្ននោះទេ សម្រាប់បទល្មើសទាំងនេះ៖ ១ក ១ខ ១គ ១ឃ ២ ៣ខ និង ៤។

សិស្សថ្នាក់មត្តេយ្យ មិនអាចបញ្ឈប់មិនឲ្យមកសាលាបណ្ដោះអាសន្នបានទេ លើកលែងតែពួកគេប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរ។ ការបញ្ឈប់បណ្ដោះអាសន្នដែលលើសពី៣ថ្ងៃ ត្រូវមានការយល់ព្រមពីអគ្គនាយករង។

អនុលោមតាមច្បាប់ ACT 26 ក្រោយពេលសវនាការ អគ្គនាយករង ឬអ្នកតំណាងរបស់គាត់ អាចសម្រេចអនុញ្ញាតឲ្យសិស្សដែលបាននាំយកអាវុធមកសាលាឲ្យនៅរៀនសាលាដដែលតទៅទៀត។

# វិន័យ និង បទល្មើស

សិស្សដែលត្រូវបានគេចាត់ទុកថាបានរំលោភបំពានលើក្រមសីលធម៌នៃអាកប្បកិរិយាសិស្សដែលបានពន្យល់នៅក្នុងផ្នែកនេះ ហើយមានការប្រជុំជាមួយសិស្ស អាចត្រូវគេធ្វើអន្តរាគមន៍ និង រងផលវិបាកទៅតាមកម្រិតដែលបានពិពណ៌នានៅក្នុងច្បាប់ និង នីតិវិធី និង សិទ្ធិ ដែលបានពិពណ៌នានៅក្នុងផ្នែកនៃ ការធ្វើអន្តរាគមន៍ និង ផលវិបាក នៃក្រមសីលធម៌នេះ។

**១ក** មិនគោរពធ្វើតាមវិន័យរបស់ថ្នាក់រៀន/ធ្វើឲ្យមានការរំខាន៖
អាកប្បកិរិយាទាំងនេះរួមមាន ប៉ុន្តែគ្មានកំណត់ចំពោះ ការរត់ ការចោលវត្ថុអ្វីមួយ ការពង្រាយ ការញ៉ាំ ការផឹក នៅកន្លែងដែលគេហាមឃាត់ ឬ អាកប្បកិរិយាដ៏ទៃទៀតដែលរំខានដល់ ការរៀនសូត្ររបស់សិស្សដទៃទៀត ឬ ការបង្រៀនរបស់គ្រូ។

**១គ** មិនកាន់ស្លាកដើរក្នុងអាគារ ឬ គ្មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ៖
ការមិនអាចបង្ហាញ ស្លាកដើរក្នុងអាគារដែលសាលាចេញឲ្យ អត្តសញ្ញាណប័ណ្ណសិស្ស ឬ អត្តសញ្ញាណប័ណ្ណដែលរដ្ឋចេញឲ្យ តាមការស្នើសុំរបស់ គ្រូ ឬ សមាជិកបុគ្គលិក របស់សាលា។

**២** គេចមិនមករៀន/មករៀនយឺតពេលច្រើនដង/គេចមិនចូលថ្នាក់រៀន៖
សិស្សដែលមកដល់ថ្នាក់ក្រោយពេលថ្នាក់ចាប់ផ្តើមជាផ្លូវការ ពី១០ដងឡើងទៅ ឬ មិនចូលរៀនក្នុងថ្នាក់តាមកាលវិភាគ ឬ ចាកចេញពីបរិវេណសាលារៀនដោយគ្មានការអនុញ្ញាត ក្នុងពេលសិក្សា។

**៣ខ** មានរបស់ផ្ទាល់ខ្លួនដែលមិនសមរម្យ៖
សិស្សដែលមាន (រួមទាំង នៅក្នុងសម្លៀកបំពាក់ ទូរដាក់សម្ភារៈ ឬ នៅក្នុងសម្លៀត របស់សិស្ស) វត្ថុណាមួយដែលមិនសមរម្យសម្រាប់ការអប់រំ (ទោះបីជា ជ្រុះ រើសបាន ឬ លួចពីគេ) (រួមទាំង រូបភាពអាសអាភាស គ្រាប់ឡុកឡាក់ បៀរ និង សម្ភារៈសម្រាប់ល្បែងស៊ីសងដ៏ទៃទៀត)។ ផលិតផល ថ្នាំជក់ បារីអេឡិចត្រូនិច ស៊ីហ្គា និង សម្ភារៈសម្រាប់ជក់ចំហាយ (**vaping kits**)។ នេះមិនរួមបញ្ចូល ដបទឹក ឬ ផលិតផលតុបតែងខ្លួននោះទេ។

**៤** ប្រើពាក្យ ឬ កាយវិការ ដែលប្រមាថមើលងាយ៖
សិស្សដែលជេរ ប្រើ ភាសា ឬ កាយវិការ អាសអាភាស។

**៥ខ** ប្រើគ្រឿងអេឡិចត្រូនិចដែលមិនសមរម្យ៖
រួមបញ្ចូលប៉ុន្តែមិនកំណត់ទៅនឹង ការផ្ញើសារអាសអាភាស (sexting) ការថតវីដេអូពីការវាយតប់គ្នា ការថតវីដេអូពីនរណាម្នាក់ដែលនៅកន្លែងឯកជន ឬ ការបង្ហោះវីដេអូពីការប្រព្រឹត្តមិនសមរម្យរបស់សិស្ស នៅក្នុងគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជះឥទ្ធិពលអវិជ្ជមានដល់សហគមន៍សាលា។

**៦** ការវាយតប់គ្នាទៅវិញទៅមក (ដោយគ្មានរបួសធ្ងន់ធ្ងរ)៖
បើសិនជាសិស្សម្នាក់ឬច្រើនវាយតប់គ្នា ដែលក្រោយពីធ្វើការស៊ើបអង្កេត គេដឹងមិនច្បាស់ថា តើសិស្សណាជាអ្នកធ្វើបាបគេ និងសិស្សណាជាជនរងគ្រោះ។

**៧** ការក្លែងបន្លំហត្ថលេខា របស់ រដ្ឋបាល គ្រូបង្រៀន ឬ មាតាបិតា/អាណាព្យាបាល៖
សិស្សណាដែលចម្លងហត្ថលេខារបស់អ្នកដទៃដោយមានចេតនាចង់ក្លែងបន្លំ។

**៨** បំផ្លែង របាយការណ៍ពិន្ទុ មូលហេតុពីការឈឺថ្នាក់ និង/ឬ ឯកសារសាលាផ្សេងៗទៀត៖
សិស្សដែលមានចេតនាចង់ក្លែងបន្លំ ផ្លាស់ប្តូររបាយការណ៍ពិន្ទុ លិខិតបញ្ជាក់មូលហេតុអវត្តមាន ឬ ឯកសារសាលាជាផ្លូវការដ៏ទៃទៀត។

**៩** បំផ្លាញ និង/ឬ លួចរបស់ទ្រព្យ (តិចជាង ៥០០$)៖
ការធ្វើឱ្យ បែកបាក់ ឬ ខូចខាត ដល់ទ្រព្យសម្បត្តិរបស់សាលា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដោយចេតនា និង ដោយការព្យាបាទ រួមបញ្ចូលប៉ុន្តែគ្មានកំណត់ទៅនឹង ការគូសវាសលេងខុសច្បាប់ បន្ទាចសាលា ដែលបណ្តាលឱ្យមានការរំខានធំធេង ឬ ការដុតបំផ្លាញ។

**១០ក** ការយាយី (រួមទាំងការយាយីលើរាងកាយ)៖
ការប្រព្រឹត្តដែលគេមិនចូលចិត្ត នៃលក្ខណៈផ្លូវភេទ ដែលអាចរួមបញ្ចូលការឆ្លៀតឱកាសផ្លូវភេទ ការសុំឲ្យគេប្រព្រឹត្តអំពើផ្លូវភេទជាមួយខ្លួន និង តាមពាក្យសម្តី កាយវិការ ឬ អំពើផ្លូវភេទ។

**១០ខ** ការសម្លុតធ្វើបាប/ការសម្លុតធ្វើបាបតាមគ្រឿងអេឡិចត្រូនិច៖
ការប្រព្រឹត្តដោយចេតនាម្តងហើយម្តងទៀតទៅលើ សិស្សណាម្នាក់ ឬ សិស្សច្រើន នៅក្នុង ឬ នៅក្រៅ សាលា ដែលមានភាពធ្ងន់ធ្ងរ ជារឿយៗ ឬ រីករាលដាល ហើយដែល (១) រំខានយ៉ាងខ្លាំងដល់ការអប់រំរបស់សិស្ស ឬ (២) បង្កើតបរិយាកាសអមិត្តនៃការសិក្សា ឬ (៣) រំខានដល់ប្រតិបត្តិការរបស់សាលា។ ការសម្លុតធ្វើបាបកើតឡើងនៅក្នុងទំនាក់ទំនងរវាងបុគ្គលដែលគ្មានតុល្យភាពនៃអំណាច (ឧ. ម្នាក់មានរូបរាងធំជាង ខ្លាំងជាង សតិអារម្មណ៍រហ័សជាង ឬ មានឥទ្ធិពលនៅក្នុងសង្គមខ្លាំងជាង)។ ការប្រព្រឹត្តអាចតាមរយៈ ផ្លូវកាយ ផ្លូវចិត្ត ពាក្យសម្តី កាយវិការ សរសេរ ឬ តាមរយៈគ្រឿងអេឡិចត្រូនិច។

ការគម្រាមកំហែងតាមអ៊ីនធឺណិតកើតឡើងតាមរយៈឧបករណ៍អេឡិចត្រូនិច រួមបញ្ចូលប៉ុន្តែគ្មានកំណត់ចំពោះ បណ្តាញសង្គម អ៊ីម៉ែល ការផ្ញើសារបន្ទាន់ សារតាមទូរស័ព្ទដៃ ទ្វីត ប្លក់ ការចែកចាយ រូបភាព និង វីដេអូ បន្ទប់ជជែកកំសាន្ត ក្តារចុច ឬ តាមវិបសៃ។

**១០គ** ការគម្រាមកំហែង៖
សិស្សដែលបង្កឲ្យមានការភ័យខ្លាច ឬអារម្មណ៍ខ្លបខ្លាច ដល់សិស្សដ៏ទៃ និង/ឬ សមាជិករបស់សហគមន៍សាលាដ៏ទៃទៀត។

**១១** ការសេពមេថុន (ដោយមានការយល់ព្រម)៖
នៅក្នុងអាគាររបស់សាលា ឬ នៅក្នុងកម្មវិធីដែលឧបត្ថម្ភដោយសាលា សិស្សដែល បង្ហាញ ឬ ប៉ះពាល់ អង្គជាតិរបស់ខ្លួន សុដន់ ឬ គូទ ឬ ផ្នែកដ៏ទៃទៀតនៃកេរ្តិ៍ខ្មាសរបស់បុគ្គលផ្សេងទៀត រួមភេទ ការរួមភេទតាមមាត់ ឬ ការរួមភេទដោយប្រើឧបករណ៍សម្រើប ដោយមានការយល់ព្រមពីអ្នកមើល និង ពីសិស្សដែលរួមចំណែក។

**១២** ការគម្រាមកំហែងដល់ សិស្ស/បុគ្គលិក ថានឹងវាយតប់គេយ៉ាងធ្ងន់ធ្ងរ៖
សិស្សដែលគម្រាមកំហែងដោយប្រើ ភាសា ការសរសេរ ឬ កាយវិការ ទាក់ទងដោយការគម្រាមកំហែងជាលក្ខណៈភេរវកម្ម ទង្វើដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់រាងកាយធ្ងន់ធ្ងរ ឬ បង្កឲ្យមានគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរដល់ សិស្ស និង/ឬ សមាជិករបស់សហគមន៍សាលាដ៏ទៃទៀត។

**១៣** បំផ្លាញ និង/ឬ លួចរបស់ទ្រព្យ (ចំនួន ៥០០$ ឬ ច្រើនជាងនេះ)៖
សិស្សដែលមានចេតនាធ្វើឱ្យ បែកបាក់ ខូចខាត ឬ យកទ្រព្យសម្បត្តិរបស់សាលា ឬ របស់បុគ្គលណាម្នាក់ ដោយគ្មានការអនុញ្ញាត។ ការបែកបាក់ ឬការខូចខាត រួមទាំង ការគូសវាសលេងខុសច្បាប់ បន្លាចសាលា ដែលបណ្តាលឲ្យមានការរំខានធំធេង ឬ ការដុតបំផ្លាញ។

**១៤** វាយបំបាក់ ហើយចូលក្នុងអាគារសាលា៖
សិស្សដែលចូលទៅក្នុងអចលនទ្រព្យដែលជាកម្មសិទ្ធិ ឬប្រើប្រាស់ដោយក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ឬ ដោយក្រុមហ៊ុនដែលនៅក្រោមកិច្ចសន្យារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា តាមរយៈការប្រើកម្លាំង (តិចបំផុត ដូចជាការរុញបើកទ្វារ) និងដោយគ្មានការអនុញ្ញាត។

**១៥ក** ចោរកម្ម៖
យក ឬ ប៉ុនប៉ងយក ទ្រព្យសម្បត្តិរបស់ សិស្ស ឬ សហគមន៍សាលា ដ៏ទៃទៀត ដោយកម្លាំង ឬ ដោយគម្រាមកំហែងដោយកម្លាំង ឬ ដោយធ្វើឲ្យជនរងគ្រោះស្ថិតនៅក្នុងសភាពភ័យខ្លាច។

**១៥ខ** ជំរិតយកប្រាក់៖
សិស្សដែលទទួលបាន លុយ ទ្រព្យសម្បត្តិ ឬ ជំនួយ ពី សិស្ស និង/ឬ សមាជិកសរបស់ហគមន៍សាលា ណាម្នាក់ ដោយបង្ហាញ ឬ ប្រើ ការគម្រាមកំហែងដោយកម្លាំង។

**១៦** វាយតប់គ្នាទៅវិញទៅមក (មានឯកសារបញ្ជាក់ថាមានរបួសធ្ងន់ធ្ងរ)៖
បើសិនជាសិស្សម្នាក់ឬច្រើនវាយតប់គ្នា ដែលក្រោយពីធ្វើការស៊ើបអង្កេត គេដឹងមិនច្បាស់ថា តើសិស្សណាជាអ្នកធ្វើបាបគេ និងសិស្សណាជាជនរងគ្រោះ។

**១៧** ការវាយតប់សមាជិករបស់សហគមន៍សាលា៖
សិស្សដែលគ្មានការញុះញង់ បាន វាយ ដាល់ ឬ ទាត់ សមាជិករបស់សហគមន៍សាលាណាម្នាក់។

**១៨** មានគ្រឿស្រវឹង និង/ឬ គ្រឿងញៀន៖
សារធាតុដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និង សារធាតុមិនស្របច្បាប់ ក៏ដូចជាអ្វីដែល «មើលទៅដូច» ដែលត្រូវបានគេកំណត់ថាជាសារធាតុដែល មានរូបរាងដូច ធ្វើជាតំណាង ឬ មានលក្ខណៈនៃការចែកចាយ ដែលបណ្តាលឲ្យគេជឿថាជា គ្រឿងញៀនខុសច្បាប់ ឬ ជាសារធាតុដែលស្ថិតនៅក្រោមការត្រួតពិនិត្យ។

**១៩** មាន ឬប្រើ កាំជ្រួច/គ្រឿងផ្ទុះផ្សេងៗ/គ្រឿងឆេះ៖
សិស្សដែលមាន (រួមទាំង នៅក្នុងសម្លៀកបំពាក់ ទូរដាក់សម្ភារៈ ឬ នៅក្នុងសម្ពៀត របស់សិស្ស) កាំជ្រួច ឧបករណ៍បំផ្ទុះ គ្រាប់បែក ផាវ សំបកគ្រាប់បែក និង/ឬ គ្រឿងផ្ទុះ ផ្សេងៗទៀត។

**២១** នាំរឿង ឬ ចូលរួមក្នុងក្រុមវាយតប់គេ៖
សិស្សដែលផ្តួចផ្តើមដោយទង្វើ ពាក្យសំដី ការសរសេរ ឬ ទង្វើ ដែលជាការវាយប្រហារតិចតួច ឬ ធ្ងន់ធ្ងរ ទៅលើសិស្សម្នាក់ ឬ ច្រើន ដូចបានកំណត់នៅក្នុងផ្នែកនេះ ដែលបញ្ជាក់ដោយសិស្សច្រើននាក់។ នេះមិនសំដៅទៅលើការវាយតប់គ្នាទៅវិញទៅមក ដូចដែលបានកំណត់នៅក្នុងផ្នែកនេះទេ ប៉ុន្តែគឺជាការវាយតប់ដែលគេបានកំណត់ថាបង្កឡើងដោយសិស្សម្នាក់ ឬ សិស្សច្រើន។

**២២** ការវាយតប់គេ៖
ទង្វើដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់រាងកាយធ្ងន់ធ្ងរ ឬបង្កើតឱ្យមានហានិភ័យនៃគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរ ដល់សិស្ស និង/ឬ សមាជិករបស់សហគមន៍សាលា ដ៏ទៃទៀត។

**២៣** ការសេពមេថុន (គ្មានការយល់ព្រម)៖
សិស្សដែលនៅក្នុងអាគាររបស់សាលា ឬ នៅក្នុងកម្មវិធីដែលឧបត្ថម្ភដោយសាលា ប៉ះពាល់អង្គជាតិរបស់ខ្លួនសុដន់ ឬ គូទ ឬ ផ្នែកដ៏ទៃទៀតនៃកេរ្តិ៍ខ្មាសរបស់បុគ្គលផ្សេងទៀត មានការបង្ខិតបង្ខំផ្លូវភេទ រួមភេទ ការរួមភេទតាមមាត់ ឬ ការរួមភេទដោយប្រើឧបករណ៍សម្រើប ដោយគ្មានការយល់ព្រមពីអ្នកមើល និង ពីសិស្សដែលរួមចំណែក (រួមទាំងការបញ្ចុះបញ្ចូល ឬ ការបង្ខិតបង្ខំ អ្នកដ៏ទៃឲ្យចូលរួមការរួមភេទ)។

**២៤** មានគ្រឿងអាវុធ៖
វត្ថុ ឬ ឧបករណ៍ ណាមួយដែលជា និងសម្រាប់ប្រើជាអាវុធ រួមទាំង កាំភ្លើង មាន ឬ គ្មាន គ្រាប់ កាំភ្លើងជ័រ (**cap guns**) កាំភ្លើងខ្យល់ (**pellet guns**) កាំភ្លើងគ្រាប់ប្រៃ (**BB guns**) កាំបិត កាំបិតកាត់ប្រអប់ ដំបងពីរកំណាត់ ឬ ត្មោង (**mace**)។ នេះមិនរាប់បញ្ចូលវត្ថុធម្មតាដូចជាខ្មៅដៃទេ។

**២៥** មិនប្រយ័ត្ន ធ្វើឲ្យអ្នកណាម្នាក់ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់៖
ចូលរួមធ្វើអំពើមិនប្រុងប្រយ័ត្ន ដែល ធ្វើឲ្យ ឬ អាចធ្វើឲ្យ អ្នកណាម្នាក់ផ្សេងទៀត ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ឬ មានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

## សិទ្ធិដែលច្បាប់ផ្តល់អោយ

គេនឹងផ្តល់ យុត្តិធម៌ និង សេចក្តីគោរព ដល់សិស្សានុសិស្សទាំងអស់។ សិស្សានុសិស្សទាំងអស់មានសិទ្ធិ ស្តាប់ និង ប្រាប់រដ្ឋបាលអំពីការបកស្រាយនៃព្រឹត្តការណ៍របស់ពួកគេ។

បើសិនជាលោកអ្នកគិតថា លោកអ្នកត្រូវការ ការបម្រើផ្នែកជនរងគ្រោះ សូមទាក់ទង អ្នកគាំទ្រ ទាមទារឲ្យសាលាមានសន្តិសុខ ទូរស័ព្ទលេខ ២១៥-៦៥៦-៥៣៨១ ឬចុលទៅវ៉ិបសៃ៖ http://ww.phillyossa.com។

## វិធីជួបប្រជុំជាមួយសិស្ស

នៅកន្លែងប្រជុំ សិស្សានុសិស្សមានសិទ្ធិដឹងថា ភ្នាក់ងារសាលានឹង៖

១. ប្រាប់សិស្សអំពីមូលហេតុនៃការប្រជុំ។
២. ផ្តល់ឱកាសឲ្យសិស្សឆ្លើយតបទៅនឹងការចោទប្រកាន់។
៣. ពិភាក្សាអំពី បញ្ហា និងវិធីកែតម្រូវអាកប្បកិរិយា របស់សិស្ស។
៤. ប្រាប់សិស្សអំពីសកម្មភាពកែតម្រូវ និង/ឬ ដំណាក់កាលបន្តបន្ទាប់មកទៀត។
៥. កត់ទុកនូវ អាកប្បកិរិយា និងការធ្វើអន្តរាគមន៍។

## វិធីបញ្ឈប់បណ្តោះអាសន្ន

យោងតាមច្បាប់រដ្ឋផិនស៊ីលវេញ៉ា ការបញ្ឈប់បណ្តោះអាសន្នបានឲ្យនិយមន័យថា៖ ការបដិសេធសិទ្ធិរបស់សិស្សមិនឲ្យមករៀន និងមិនឲ្យចូលរួមក្នុងកម្មវិធីអ្វីមួយនៅសាលា ដែលអាចមានរយៈពេលរហូតដល់ទៅ ១០ថ្ងៃ។ ការបញ្ឈប់បណ្តោះអាសន្ន ត្រូវធ្វើឡើងបន្ទាប់ពីមានការបញ្ជាក់ប្រាប់ដល់សិស្ស និងមាតាបិតា/អាណាព្យាបាល តាមរយៈលិខិតស្នាម។ ជាគោលបំណងនៃក្រមសីលធម៌នៃអាកប្បកិរិយាសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ានេះ ការបញ្ឈប់បណ្តោះអាសន្នត្រូវបានបែងចែកជាបីផ្នែក៖ នៅក្នុងសាលា រយៈពេលខ្លី និង រយៈពេលយូរ។

## ការបញ្ឈប់បណ្តោះអាសន្ននៅក្នុងសាលា

**<u>ការបញ្ឈប់បណ្តោះអាសន្ននៅក្នុងសាលា</u>** គឺជាការមិនឲ្យចូលរួមក្នុងថ្នាក់រៀន សម្រាប់គោលបំណងនៃការដាក់វិន័យ ប៉ុន្តែឲ្យសិស្ស **នៅតែ**នៅក្រោមការមើលខុសត្រូវផ្ទាល់របស់បុគ្គលិកសាលា។ មើលការខុសត្រូវផ្ទាល់ មានន័យថា បុគ្គលិកសាលានៅជាមួយសិស្ស ពេលសិស្សស្ថិតនៅក្រោមការមើលខុសត្រូវរបស់គាត់។

## ការបញ្ឈប់បណ្តោះអាសន្ននៅក្រៅសាលា

**<u>មិនអាចបញ្ឈប់សិស្សថ្នាក់មត្តេយ្យ បណ្តោះអាសន្នបានទេ លើកលែងតែសកម្មភាពរបស់ពួកគេបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ</u>**

**<u>ការបញ្ឈប់បណ្តោះអាសន្ន រយៈពេលខ្លី</u>** គឺជាការមិនឲ្យមកសាលា និង/ឬ មិនឲ្យចូលរួមសកម្មភាព ឬពិធី អ្វីមួយនៅសាលា អស់រយៈពេល **បី (៣) ថ្ងៃ ឬតិចជាងនេះ**។ សិស្សានុសិស្សដែលត្រូវគេបញ្ឈប់បណ្តោះអាសន្ន នឹងជួបជាមួយនាយកសាលា ឬអ្នកតំណាងរបស់គាត់ មុនពេលទទួលទណ្ឌកម្ម។ នៅពេលប្រជុំ សិស្សមានសិទ្ធិ ស្របទៅតាមវិធីផ្សេងៗដែលបានរៀបរាប់នៅក្នុង *វិធីសាស្ត្រនៃការជួបប្រជុំជាមួយសិស្ស* ដែលលើកឡើងនូវចំណុចសំខាន់ៗ នៅក្នុងក្រមសីលធម៌នៃអាកប្បកិរិយាសិស្សនេះ។

**<u>ការបញ្ឈប់បណ្តោះអាសន្ន រយៈពេលយូរ</u>** គឺជាការមិនឲ្យមកសាលា និង/ឬ មិនឲ្យចូលរួមសកម្មភាព ឬពិធីអ្វីមួយនៅសាលា អស់រយៈពេល **បួន (៤) ទៅ ១០ថ្ងៃ នៃថ្ងៃសិក្សា។** សិស្សានុសិស្សដែលទទួលការបញ្ឈប់បណ្តោះអាសន្ន រយៈពេលយូរ ត្រូវចូលរួមការជួបប្រជុំជាមួយសិស្ស និងការជួបប្រជុំជាមួយមាតាបិតា។ នៅពេលប្រជុំជាមួយមាតាបិតា សិស្ស និងមាតាបិតា មានសិទ្ធិស្របទៅតាមវិធីផ្សេងៗដែលបានរៀបរាប់នៅក្នុង*វិធីសាស្ត្រនៃការជួបប្រជុំជាមួយមាតាបិតា* ដែលលើកឡើងនូវចំណុចសំខាន់ៗ នៅក្នុង ក្រមសីលធម៌នៃអាកប្បកិរិយាសិស្សនេះ។ ជាបន្ថែមទៀត ការដាក់ទណ្ឌកម្មរយៈពេលយូរ តម្រូវឲ្យមានការយល់ព្រមជាមុនពី អនុអគ្គលេខាធិការ។ **ជាបន្ថែមទៀត តម្រូវឲ្យមានការយល់ព្រមជាមុនពីនាយករង នៃការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់សិស្ស ចំពោះការបញ្ឈប់បណ្តោះអាសន្នទាំងអស់ ដែលមានរយៈពេលលើសពី ៨ថ្ងៃ នៃថ្ងៃសិក្សា។**

**ការបញ្ជូនទៅ ការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់សិស្ស សម្រាប់សវនាការដាក់វិន័យទាំងអស់ ត្រូវតែមានការបញ្ឈប់មិនឲ្យមានសាលាជាបណ្តោះអាសន្ន ជាមុនសិន។**

## វិធីជួបប្រជុំជាមួយមាតាបិតា

នៅកន្លែងប្រជុំ មាតាបិតា អាណាព្យាបាល និងអ្នកមើលថៃក្មេង អាចមានជំនឿថា រដ្ឋបាលសាលានឹងធ្វើតាមនីតិវិធីដូចតទៅ៖

១. លិខិតផ្តល់ដំណឹងអំពីការប្រជុំត្រូវតែផ្តល់ជូន មាតាបិតា/អាណាព្យាបាល តាមការសរសេរជាលិខិត ហើយយកទៅប្រគល់ឲ្យដល់ផ្ទះ ផ្ញើតាមប៉ុស្តិ៍សំបុត្រដោយមានការបញ្ជាក់ តាមទូរសារ អ៊ីមែល ឬផ្ញើតាមវិធីផ្សេងៗទៀតដែលសមហេតុសមផល ដើម្បីឲ្យបានទៅដល់ មាតាបិតា/អាណាព្យាបាល។
២. នៅពេលណាសិស្សត្រូវគេបញ្ឈប់ជាបណ្តោះអាសន្ន ត្រូវមានការជួបប្រជុំជាមួយ មាតាបិតា/អាណាព្យាបាល ក្នុងកំឡុងពេល បី (៣) ថ្ងៃ នៃការបញ្ឈប់ជាបណ្តោះអាសន្ន។
៣. នៅក្នុងអង្គប្រជុំ មាតាបិតា/អាណាព្យាបាល ឬអ្នកមើលថៃក្មេង អាចស្នើសុំពិនិត្យមើលឡើងវិញ និងសុំសំណុំរឿងរបស់សិស្សមួយច្បាប់ និងសេចក្តីរាយការណ៍របស់សាក្សី ដែលឈ្មោះសិស្សដទៃទៀត និង ព័ត៌មានមួយចំនួន ត្រូវបានគេកែសម្រួល។
៤. រដ្ឋបាលសាលានឹងពិភាក្សាអំពី បញ្ហា និងវិធីកែតម្រូវអាកប្បកិរិយា របស់សិស្ស។
៥. រដ្ឋបាលសាលានឹងជម្រាបមាតាបិតា/អាណាព្យាបាល អំពីការដាក់វិន័យបន្ថែមទៀត។

## វិធីផ្លាស់ប្តូរនៃការដាក់វិន័យសិស្ស

**សិស្សថ្នាក់មត្តេយ្យដល់ថ្នាក់ទី៥ មិនអាចបញ្ជូនទៅសវនាការនៃការដាក់វិន័យទេ។ មុនពេលអាចធ្វើការបញ្ឈប់បណ្តោះអាសន្នដល់សិស្សថ្នាក់ទី ១ និងថ្នាក់ទី ២ ត្រូវមាន ការបញ្ជូនដើម្បីធ្វើអន្តរាគមន៍នានា និងចងក្រងទុកជាឯកសារ។ សូមមើលទំព័រទី ៧ នៃ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ដើម្បីជ្រាបព័ត៌មានលម្អិត។**

សិស្សថ្នាក់មត្តេយ្យដល់ថ្នាក់ទី៥ ដែលធ្លាប់មានអាកប្បកិរិយារំខានគេឯង និង/ឬ បំពានលើ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ទាំងនោះ ត្រូវគេបញ្ជូនទៅ វិធីសាស្ត្រនៃប្រព័ន្ធពហុដំណាក់កាលនៃការគាំទ្រ (MTSS)។

សិស្សានុសិស្សថ្នាក់ទី៦ដល់ថ្នាក់ទី១២ ដែលធ្លាប់មានអាកប្បកិរិយារំខានគេឯង និង/ឬ បំពានលើ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស គេអាចបញ្ជូនទៅ ការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់ សិស្ស សម្រាប់ សវនាការនៃការដាក់វិន័យសិស្ស។ សិស្សានុសិស្សដែលត្រូវគេបញ្ជូនទៅ មានសិទ្ធិដែលច្បាប់បានផ្តល់ឲ្យយ៉ាងពេញលេញ រួមទាំង ការធ្វើសវនាការដើម្បីសម្រេចថាតើសិស្សនឹងត្រូវប្តូរទៅសាលាដែលមានវិន័យតឹងតែង ឬអត់។ សាលាទាំងនេះផ្តល់កម្មវិធីអប់រំតាមវិធីផ្សេងៗដែលមានគុណភាពខ្ពស់ និងជំនួយដើម្បីជួយសិស្សានុសិស្សឲ្យសម្រេចទៅតាមកម្រិតនៃ ប្រាជ្ញាស្មារតី និង ទំនាក់ទំនងនៅក្នុងសង្គម របស់ពួកគេ។

## ការចាត់តាំងបណ្តោះអាសន្ន

សិស្សានុសិស្សដែលត្រូវគេបញ្ជូនសម្រាប់សវនាការ ត្រូវគេបញ្ឈប់ជាបណ្តោះអាសន្ន និងប្រាប់ពីនីតិវិធី ដែលបានបញ្ជាក់ក្នុង វិធីបញ្ឈប់បណ្តោះអាសន្ន នៅក្នុងក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។ សាលាក៏ត្រូវតែបំពេញលិខិតពិនិត្យមើលលក្ខណសម្បត្តិ សម្រាប់សិស្សដែលទទួលការអប់រំធម្មតា ឬបង្ហាញនូវសេចក្តីសម្រេចចិត្ត សម្រាប់សិស្សដែលទទួលការអប់រំពិសេស ហើយជម្រាបពីលទ្ធផលនៃការពិ និត្យនេះ នៅពេលជួបប្រជុំជាមួយមាតាបិតា/អាណាព្យាបាល។ **នៅពេលដែលគេមិនបានកំណត់ពេលសម្រាប់សវនាការ ក្នុងកំឡុងពេលដែលគេបញ្ឈប់សិស្សជាបណ្តោះអាសន្ន សិស្សមានសិទ្ធិត្រឡប់ទៅរៀននៅសាលារបស់ខ្លួនវិញ ដោយរង់ចាំលទ្ធផលនៃសវនាការ លើកលែងតែអាកប្បកិរិយារបស់សិស្សនៅតែបន្តឲ្យមានគ្រោះថ្នាក់ដល់សហគមន៍សាលា បន្ទាប់មក សាលាអាចស្នើសុំការចាត់តាំងបណ្តោះអាសន្ន។ (សូមមើលវិធីសាស្ត្រលម្អិតខាងក្រោមនេះ)។**

សិស្សានុសិស្ស/មាតាបិតា/អាណាព្យាបាល មានសិទ្ធិចំពោះសវនាការ ដែលធ្វើឡើងដោយភ្នាក់ងារសវនាការឯករាជ្យ និងមិនលំអៀង។ ក្នុងពេលរៀបវីធីសវនាការ មាតាបិតា/អាណាព្យាបាល អាចមានសិទ្ធិជំទាស់នឹងការស្នើសុំដកសិស្សចេញពីសាលារបស់ពួកគេ។ នៅទីសវនាការ សិស្សានុសិស្ស និង មាតាបិតា/អាណាព្យាបាល មានសិទ្ធិ៖

- នាំសាក្សីមកជាមួយ
- បង្ហាញភស្តុតាងដែលទាក់ទងនឹងបទល្មើសដែលបានចោទប្រកាន់
- ស្នើសុំ និងសួរសំណួរ ទៅបុគ្គលិករបស់ក្រសួងអប់រំ និង
- ពិនិត្យមើលសំណុំរឿងសិស្សជាមុន

បើសិនជាភ្នាក់ងារសវនាការរកឃើញថា ការចោទប្រកាន់នៃបទល្មើសនោះបានកើតឡើងមែន គាត់នឹងសម្រេចឲ្យមានការដាក់វិន័យ ដែលសមស្របទៅតាមកម្រិត ដែលអាចធ្វើទៅបាននៃបទល្មើសនោះ។

សាលាអាចស្នើសុំការចាត់តាំងបណ្តោះអាសន្ន សម្រាប់សិស្សដែលរៀនក្នុងកម្មវិធីសិក្សាធម្មតា បើមានឯកសារបញ្ជាក់ថា ការមករៀនជាបន្តរបស់សិស្ស នាំឲ្យមានការគម្រាមកំហែងដល់សុវត្ថិភាពរបស់សហគមន៍សាលា។ ក្នុងករណីទាំងនេះ នៅពេលដែល ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស ផ្តល់ការចាត់តាំងបណ្តោះអាសន្នរួចហើយ គឺត្រូវមានសវនាការជាបន្ទាន់ ក្រោយពេលការចាត់តាំងនេះ។ សម្រាប់សិស្សដែលមានការអប់រំពិសេស ការចាត់តាំងបណ្តោះអាសន្ននឹងធ្វើឡើងតែបើសិនណាមានឯកសារបញ្ជាក់ថាមាន អាវុធ គ្រឿងញៀន ឬ របួសធ្ងន់ធ្ងរ តែប៉ុណ្ណោះ។

កំណត់សម្គាល់៖ សូមមើលក្នុងជំពូកនៃ**ការដាក់វិន័យចំពោះសិស្សពិការ** សម្រាប់ពិធីដាក់វិន័យ ចំពោះសិស្សពិការ។

## វិធីដេញសិស្សចេញ

យោងតាមច្បាប់រដ្ឋផិនស៊ីលវេញ៉ា ការដេញសិស្សចេញ មានអត្ថន័យថា ការដេញសិស្សចេញពីសាលា និងសកម្មភាពផ្សេងៗនៅសាលា សម្រាប់ រយៈពេល១០ថ្ងៃ នៃថ្ងៃសិក្សាឡើងទៅ។ សិស្សដែលប្រព្រឹត្តិបទល្មើសដែលបណ្តាលឲ្យមានការដេញចេញ ក៏ត្រូវគេបញ្ឈប់មិនឲ្យមករៀន និងមានសិទ្ធិទៅតាមនីតិវិធី ដែលបានរៀបរាប់នៅក្នុងវិធីសាស្ត្រនៃការបញ្ឈប់បណ្តោះអាសន្ន ដែលបានលើកឡើងនូវចំណុចសំខាន់ៗ នៅក្នុង ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។

***សវនាការនៃការដេញសិស្សចេញ រួមទាំងការតម្រូវតាមច្បាប់នៃការគោរពសិទ្ធិរបស់បុគ្គល៖***

១. ផ្តល់ដំណឹងអំពីការចោទប្រកាន់ តាមការសរសេរជាលាយលក្ខណ៍អក្សរ ផ្ញើតាមប៉ុស្តិ៍សំបុត្រដោយមានការបញ្ជាក់ ទៅមាតាបិតា/អាណាព្យាបាល។

២. ត្រូវផ្តល់លិខិតជូនដំណឹងអំពី ពេលវេលា និងទីកន្លែង សវនាការ យ៉ាងហោចណាស់បី (៣) ថ្ងៃមុន ហើយរួមទាំង ច្បាប់ចម្លងនៃច្បាប់នេះ វិធីធ្វើសវនាការ និងលិខិតជូនដំណឹងអំពីសិទ្ធិអាចរកមេធាវីមកធ្វើជាតំណាង។ សិស្សអាចស្នើសុំដូរថ្ងៃសវនាការ បើពួកគេអាចផ្តល់មូលហេតុសមរម្យ នៃការសុំពន្យាពេលនេះ។

៣. សវនាការនឹងធ្វើឡើងដោយឡែកៗ លើកលែងតែ សិស្ស ឬ មាតាបិតា/អាណាព្យាបាលសុំឲ្យធ្វើជាសាធារណៈ។

៤. មាតាបិតា/អាណាព្យាបាល ជាអ្នកចេញថ្លៃឲ្យជាមេធាវីដែលជាអ្នកតំណាង ហើយ មាតាបិតា/អាណាព្យាបាល អាចចូលរួមក្នុងសវនាការបាន។

៥. ការបញ្ចេញឈ្មោះសាក្សីដែលប្រឆាំងនឹងសិស្ស និងសេចក្តីថ្លែងការណ៍របស់ពួកគេ ឬ លិខិត បញ្ជាក់ភស្តុតាង មួយច្បាប់។

៦. សិទ្ធិស្នើសុំឲ្យសាក្សីដែលប្រឆាំងនឹងសិស្សមកបង្ហាញខ្លួន ហើយឆ្លើយសំណួរ ឬ ធ្វើការសួរបញ្ជាក់។

៧. សិទ្ធិមកឡើងមកស្រាយបំភ្លឺ ជជែកវែកញែក និងផ្តល់សាក្សីឲ្យសិស្ស

៨. ត្រូវរក្សា ការកត់ត្រាទុក ឬ អាត់សម្លេង អំពីសវនាការ ហើយត្រូវមានមួយច្បាប់សម្រាប់សិស្ស ដែលសិស្សត្រូវចេញថ្លៃ ឬឥតយកថ្លៃបើសិនជាសិស្សទីទ័លក្រ។

៩. សវនាការនឹងប្រព្រឹត្តិទៅក្នុងកំឡុងពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃសិក្សា ចាប់ពីថ្ងៃជូនដំណឹង អំពីការចោទប្រកាន់ លើកលែងតែមានការពន្យាពេលតាមការយល់ព្រមទាំងសងខាង ឬ ត្រូវពន្យាពេលដោយសារ៖
   - ក. ត្រូវការរបាយការណ៍ពីមន្ទីរពិសោធន៍ ពីអង្គការផ្នែកអនុវត្តច្បាប់។
   - ខ. ការវាយតម្លៃ ឬ ដំណើរការនីតិវិធីនៃតុលាការ ឬ រដ្ឋបាល ត្រូវពន្យាពេល ដោយសារសិស្សយកសិទ្ធិរបស់គេមកប្រើ តាមច្បាប់អប់រំអ្នកពិការ (IDEA)។
   - គ. ចាំបាច់ត្រូវពន្យាពេល ដោយសារស្ថានភាព ឬ ជាការល្អ សម្រាប់ជនរងគ្រោះ សម្រាប់តុលាការ យុវវ័យ ឬ តុលាការព្រហ្មទ័ណ្ឌ ដែលទាក់ទងនឹងការរំលោភ ឬ មានរបួសធ្ងន់ធ្ងរ។

១០. ត្រូវផ្តល់ជូននូវលិខិតជូនដំណឹងអំពីសិទ្ធិនៃការតវ៉ាចំពោះលទ្ធផលនៃសវនាការ ដល់សិស្សដែលមានការសម្រេចថាត្រូវបណ្តេញចេញពីសាលា។

## វិធីដេញសិស្សចេញ (ត)

បើសិនជាសិស្សត្រូវបណ្ដេញចេញដោយ គណកម្មាធិការកែទម្រង់សាលារៀន មាតាបិតា/អាណាព្យាបាល របស់សិស្ស មានពេល៣០ថ្ងៃ ដើម្បីផ្ដល់ឯកសារតាមការសរសេរជាលាយលក្ខណ៍អក្សរ បញ្ជាក់ថាសិស្សរៀននៅក្នុងកម្មវិធីអប់រំផ្សេងទៀត។ បើសិនជាពួកគេមិនអាចរកកម្មវិធីអប់រំតាមវិធីផ្សេងទៀតបាន ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា នឹងផ្ដល់ការអប់រំដល់សិស្ស។

សិស្សដែលត្រូវគេដេញចេញពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ជាអចិន្ត្រៃយ៍ តាមការបោះឆ្នោតសម្រេចដោយសម្លេងភាគច្រើនរបស់គណៈកម្មាធិការកែទម្រង់សាលារៀន អាចដាក់ពាក្យសុំចូលរៀននៅក្រសួងអប់រំវិញ។

គណៈកម្មាធិការកែទម្រង់សាលារៀន ឲ្យអំណាចទៅ នាយកប្រតិបត្តិ/អគ្គនាយក ឬអ្នកតំណាង របស់គាត់ ដើម្បីសម្រេចនូវការទទួលសិស្សឲ្យចូលរៀនវិញទាំងអស់។ សិស្សដែលត្រូវគេដេញចេញបណ្ដោះអាសន្ន មិនបាច់ដាក់ពាក្យសុំចូលរៀនវិញទេ ដោយសារពួកគេអាចចូលរៀននៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា វិញដោយស្វ័យប្រវត្ត នៅពេលផុតកំណត់ពេលដែលត្រូវគេដេញចេញ។ ការសម្រេចឲ្យចូលរៀនវិញគឺជាការសម្រេចចុងក្រោយបង្អស់ ហើយមិនចាំបាច់មានការពិនិត្យឡើងវិញ តាមរយៈការសុំតវ៉ាទៅ គណៈកម្មាធិការកែទម្រង់សាលារៀន ឬតុលាការ ទេ។

## ការលប់ចោលឯកសាររបស់សិស្សដែលត្រូវគេដេញចេញ

សិស្សដែលត្រូវគេដេញចេញជាអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្ន តាមការបោះឆ្នោតសម្រេចដោយសម្លេងភាគច្រើនរបស់គណៈកម្មាធិការកែ ទម្រង់សាលារៀន ចាប់ផ្ដើមក្នុងឆ្នាំសិក្សា២០០៨-២០០៩ អាចដាក់ពាក្យសុំទៅ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដើម្បីដកឯកសារនៃ ការដេញសិស្សចេញពីសំណុំឯកសារសិស្ស ឬ លប់ចោល។ ការលប់ចោល កើតមានឡើងក្រោមការដឹកនាំរបស់ អគ្គនាយក ឬ អ្នកតំណាងរបស់គាត់ ហើយមិនចាំបាច់មានការពិនិត្យឡើងវិញ ឬសុំតវ៉ាទៅ គណៈកម្មាធិការកែ ទម្រង់សាលារៀន ឬតុលាការ នោះទេ។

ដើម្បីមើលច្បាប់របស់គណៈកម្មាធិការកែទម្រង់សាលារៀន លេខ២៣៣ ដែលមានលក្ខណវិនិច្ឆ័យ និងវិធីសម្រាប់ការទទួលសិស្សឲ្យចូលរៀនវិញ និង ឬការលុបចោលសំណុំរឿង សូមមើលក្នុងវ៉ិបសៃរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា - http://www.philasd.org/offices/administration/policies

## វិន័យសម្រាប់សិស្សពិការ

**ការបញ្ឈប់បណ្ដោះអាសន្ន សម្រាប់សិស្សដែលទទួលការអប់រំពិសេស ដែលគេបានដឹងថាពិការផ្នែកសតិបញ្ញា**

ក្រសួងអប់រំអាចបញ្ឈប់សិស្សដែលគេបានដឹងថាពិការផ្នែកសតិបញ្ញា បណ្ដោះអាសន្ន តែក្នុងករណីមានកិច្ចព្រមព្រៀងជាលិខិតស្នាមពីមាតាបិតា/អាណាព្យាបាល ឬការសរសេរយល់ព្រមពីការិយាល័យអប់រំសិស្សពិការ របស់ក្រសួងអប់រំ នៃរដ្ឋផិនស៊ីលវេញ៉ា។ ក្រសួងអប់រំ នៃរដ្ឋផិនស៊ីលវេញ៉ា អាចទាក់ទងទៅក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ាដោយទូរស័ព្ទទៅលេខ ៧១៧-៧៨៣-៦៩១៣ ឬមើលវ៉ិបសៃ - http://www.pde.state.pa.us

**ការបញ្ឈប់បណ្ដោះសន្ន ការដេញចេញ និងការផ្លាស់ប្ដូរ សម្រាប់សិស្សពិការទាំងអស់ – រួមទាំងសិស្សដែលទទួលការបម្រើក្រោមកិច្ចព្រមព្រៀង នៃមាត្រា៥០៤**

ក្រសួងអាចបញ្ឈប់សិស្សពិការបណ្ដោះអាសន្ន និងបញ្ឈប់ការអប់រំរហូតដល់ទៅប្រាំ (៥) ថ្ងៃ នៃថ្ងៃសិក្សា ផ្ទួនៗគ្នា ឬ ១៥ ថ្ងៃ នៃថ្ងៃសិក្សា សរុបក្នុង១ឆ្នាំសិក្សា ដោយមិនបាច់ផ្ដល់ឯកសារ វិធីសាស្ត្រការពារ សម្រាប់ការអប់រំពិសេស (special education procedural safeguards)។

សាលាត្រូវតែធ្វើតាមគ្រប់ដំណាក់កាលដូចតទៅ ដំណាក់កាល A ដល់ G ខាងក្រោមនេះ សម្រាប់សិស្សានុសិស្សដែលមាន គម្រោងការអប់រំផ្ទាល់ខ្លួន (IEP) ឬ ការបម្រើក្រោមកិច្ចព្រមព្រៀងនៃមាត្រា ៥០៤ បើសិនជាត្រូវធ្វើតាមវិធីអ្វីមួយដូចខាងក្រោមនេះ៖

១. ការផ្ដល់យោបល់ ឲ្យដេញចេញ។
២. ស្នើសុំឲ្យផ្លាស់ទៅសាលាអប់រំតាមវិធីផ្សេងទៀត ដោយសារការដាក់វិន័យ (សាលាត្រូវតែបំពេញលិខិត EH-21)។
៣. ការបញ្ឈប់បណ្ដោះអាសន្នដែលមានរយៈពេលលើសពី១០ថ្ងៃផ្ទួនៗគ្នា។
៤. ការបញ្ឈប់បណ្ដោះអាសន្នដែលមានរយៈពេលលើសពី១៥ថ្ងៃផ្ទួនៗគ្នា។
៥. ការបញ្ឈប់បណ្ដោះអាសន្នដែលសរុបទៅលើសពី ១០ ថ្ងៃ ក្នុង១ឆ្នាំសិក្សា និងពេលណាមាន អាកប្បកិរិយា ដដែលៗ។

**ដំណាក់កាល៖**

ក្នុងកំឡុងពេល២៤ម៉ោង ចាប់ពីពេលមានបទល្មើស បុគ្គលិកមួយក្រុម ត្រូវមានការប្រជុំសម្រេច ហើយត្រូវមានការអញ្ជើញមាតាបិតា/អាណាព្យាបាល ឲ្យចូលរួម។ ក្រុមនេះត្រូវតែ៖

ក) ផ្ដល់លិខិតជូនដំណឹងទៅ មាតាបិតា/អាណាព្យាបាល អំពីសំណូមពរដាក់វិន័យ និងថ្ងៃខែប្រជុំ របស់ក្រុមអំពី គម្រោងការអប់រំផ្ទាល់ខ្លួន (IEP) ។

ខ) នៅពេលប្រជុំសម្រេច IEP ក្រុម IEP នឹងពិនិត្យមើលនូវការវាយតម្លៃថ្មីៗរបស់សិស្ស និង IEP របស់សិស្ស និងការចាត់តាំងសិស្ស ដើម្បីសម្រេចថាតើ បទល្មើសរបស់សិស្ស ទាក់ទងនឹង ពិការភាព ឬអត់។ នៅពេលប្រជុំសម្រេច ក្រុមរបស់សាលាត្រូវឆ្លើយនូវសំណួរពីរ៖ (១) តើបទល្មើសបណ្ដាល មកពី ឬតើវាជាប់ទាក់ទងនឹងពិការភាពរបស់សិស្សឬទេ? ឬ (២) តើបទល្មើស ដែលគេកំពុងសួរដេញដោលកើតឡើងដោយសារសាលាមិនបានអនុវត្ត IEP សម្រាប់សិស្ស ឬយ៉ាងណា?

គ) បើសិនជាក្រុមរបស់សាលាសម្រេចថា អាកប្បកិរិយារបស់សិស្ស **មិនមែន** បណ្ដាលមកពីពិការភាពទេ ភ្នាក់ ងារសាលាអាចធ្វើតាម ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។ ទោះជាយ៉ាងនេះក្ដី នៅក្នុងករណីណាក៏ដោយ គេមិនអាចបញ្ឈប់ដោយគ្មានជំនួយនូវការអប់រំត្រឹមត្រូវដល់សិស្ស លើសពីប្រាំ (៥) ថ្ងៃផ្ទួនៗគ្នា ឬ ដប់ប្រាំ (១៥) ថ្ងៃ ក្នុងមួយឆ្នាំសិក្សា បានទេ។

ឃ) ត្រូវចេញ លិខិតសំណូមពរចាត់តាំងការអប់រំ-A Notice of Recommended Educational Placement (NOREP) ជាមួយនឹងលទ្ធផលនៃការសម្រេចនេះ និងវិធីការពារមួយច្បាប់ ជូនទៅ មាតាបិតា/អាណាព្យាបាល។

***បើសិនជា មាតាបិតា ឬអាណាព្យាបាល មិនយល់ស្របតាមការសម្រេចនេះទេ គាត់អាចស្នើសុំឲ្យមានសវនាការ នៃការអប់រំពិសេស ជាបន្ទាន់** ហើយរដ្ឋនឹងតែងតាំងភ្នាក់ងារសវនាការ ដើម្បីពិនិត្យមើលឡើងវិញនូវ ការសម្រេចនេះ។

ង) បើសិនជាចាំបាច់ ក្រុម IEP នឹងពិនិត្យឡើងវិញ ហើយកែសម្រួលគម្រោងការធ្វើអន្តរាគមន៍ចំពោះអាកប្បកិរិយា ដែលមានរួចមកហើយ ឬ បើសិនជាចាំបាច់ នឹងធ្វើការវាយតម្លៃមើលអាកប្បកិរិយា និងគម្រោងការធ្វើអន្តរាគមន៍ ដើម្បីដោះស្រាយកំហុសឆ្គងនេះ។

## វិន័យសម្រាប់សិស្សពិការ (ត)

ច) ក្រុម IEP នឹងសម្រេចនូវការអប់រំតាមវិធីផ្សេងទៀតជាបណ្ដោះអាសន្នដែលសមរម្យ និងដូចបានបញ្ជាក់រួចមក ហើយនៅក្នុង IEP ជំនួយ និងការកែប្រែទាំងនោះ ដែលអាចធ្វើឲ្យសិស្សបន្តការចូលរួមក្នុងកម្មវិធីសិក្សាទូទៅ និងកែតម្រូវអាកប្បកិរិយា ដើម្បីកុំឲ្យកើតមានឡើងម្ដងទៀត។

ឆ) បើសិនជាអាកប្បកិរិយារបស់សិស្ស **បណ្ដាលមកពីពិការភាព** ការចាត់តាំងសិស្សមិនអាចផ្លាស់ប្ដូរបានទេ លុះ ត្រាតែ៖

(១) សិស្សយកគ្រឿងអាវុធដែលអាចបណ្ដាលឲ្យមានគ្រោះថ្នាក់មកសាលា* ឬមកក្នុងពិធីអ្វីមួយនៅសាលា។

(២) សិស្ស មាន ឬប្រើ គ្រឿងញៀន ឬលក់ ឬរកអ្នកណាម្នាក់ឲ្យលក់វត្ថុខុសច្បាប់នៅក្នុង សាលា ឬពិធីអ្វីមួយនៅសាលា ដោយចេតនា ហើយ

(៣) សិស្សធ្វើឲ្យអ្នកដទៃមានរបួសធ្ងន់ធ្ងរ នៅក្នុង សាលា ក្នុងបរិវេណសាលា ឬពេលមានពិធីអ្វីមួយនៅសាលា។ ក្នុងកាលៈទេសៈពិសេសៗទាំងនេះ និង**លើការជំទាស់ របស់មាតាបិតា/អាណាព្យាបាល** ភ្នាក់ងារសាលាអាចដកសិស្សចេញ ដោយចេញលិខិតសំណូមពរចាត់តាំងការអប់រំ (NOREP) ទៅឲ្យការអប់រំតាមវិធីផ្សេងទៀតជាបណ្ដោះអាសន្ន សម្រាប់រយៈពេលមិនលើសពី៤៥ថ្ងៃ។

- បើសិនជាអាកប្បកិរិយារបស់សិស្ស ត្រូវបានគេសម្រេចថា បណ្ដាលមកពីពិការភាព របស់សិស្ស ហើយបទល្មើសនេះមិនស្ថិតនៅក្នុង "កាលៈទេសៈពិសេស" ណាមួយទេនោះ (សូមមើល G. ១-៣ ខាងលើ) ហើយបើសិនជាការរក្សាទុកការចាត់តាំងនាពេលបច្ចុប្បន្នឲ្យនៅដដែល សិស្សអាចបណ្ដាលឲ្យមានរបួសដល់ខ្លួនឯង ឬដល់អ្នកដទៃទៀត ក្រសួងអាចសុំឲ្យមានសវនាការ ដោយរួសរាន់ ដែលធ្វើឡើងដោយភ្នាក់ងារសវនាការផ្នែកអប់រំពិសេស (Special Education Hearing Officer) ដើម្បីស្នើសុំឲ្យភ្នាក់ងារសវនាការ ធ្វើការចាត់តាំងសិស្សជាបណ្ដោះអាសន្ន ចំនួន៤៥ថ្ងៃ។
- សិស្សពិការ ទោះជាត្រូវគេដេញចេញពីសាលាក៏ដោយ គេត្រូវតែផ្ដល់ការអប់រំជាសាធារដោយឥតគិតថ្លៃ និងសមរម្យ។

***កំណត់សម្គាល់៖** "គ្រឿងអាវុធដែលប្រកបដោយគ្រោះថ្នាក់" គឺជាគ្រឿងអាវុធ ឧបករណ៍ សម្ភារៈ ឬវត្ថុ ដែលគេអាចប្រើ ឬអាចបណ្ដាលឲ្យស្លាប់ ឬរបួសធ្ងន់ធ្ងរ។ ទោះជាយ៉ាងដូច្នេះក្ដី ចំពោះកាំបិតបត់សម្រាប់ដាក់ក្នុងហោប៉ៅដែលមានផ្លែខ្លីជាង ៦,៣៥ ស.ម. មិនរាប់ថាជាអាវុធដែលប្រកបដោយគ្រោះថ្នាក់ទេ។ ឧបករណ៍សម្រាប់កាត់របស់ជាច្រើនគឺជា "គ្រឿងអាវុធដែលប្រកបដោយគ្រោះថ្នាក់។"

---

ព័ត៌មានដែលមាននៅក្នុងកូនសៀវភៅនេះ អាចមានការកែបន្ថែម ដើម្បីផ្ដល់ព័ត៌មានថ្មីៗ នៅក្នុងកំឡុងឆ្នាំសិក្សា។

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer

ទូរស័ព្ទ៖ ២១៥-៤០០-៨៤៨៤

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មិនរើសអើងក្នុងការជួលអ្នកធ្វើការ ឬកម្មវិធីអប់រំ ឬសកម្មភាពផ្សេងៗ ដោយយោងទៅលើ ពូជសាសន៍ ជំនឿ ពណ៌សម្បុរ ជាតិកំណើត សាសនា ពូជពង្ស អាយុ រៀបការឬមិនទាន់រៀនការ ទំនោរនៃសេចក្ដីស្រឡាញ់ (បានដឹង ឬ យល់ឃើញ) ការបង្ហាញពីអត្តសញ្ញាណអំពីភេទ (បានដឹង ឬ យល់ឃើញ) ភេទ ពិការភាព សញ្ជាតិ ការចូលសញ្ជាតិ សមាជិកសហជីព ឬមិនសូវចេះភាសាអង់គ្លេស នោះទេ។ ច្បាប់មិនរើសអើងនេះ គឺសម្រាប់អ្នកដែលមានសិទ្ធិនៅក្រោមច្បាប់ការពារទាំងអស់។ ការបោះពុម្ពឯកសារនេះគឺស្របតាមច្បាប់ រដ្ឋ និងរដ្ឋសហព័ន្ធ រួមទាំង ច្បាប់ Title IX ដែលជាច្បាប់កែសម្រួលការសិក្សានៃឆ្នាំ១៩៧២ និងមាត្រា ៥០៣ និង ៥០៤ នៃច្បាប់ជនពិការឆ្នាំ១៩៧៣។

THE SCHOOL DISTRICT OF
PHILADELPHIA

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា**
**មជ្ឍមណ្ឌលអប់រំ**
440 North Broad Street
Philadelphia, PA 19130